# កិច្ចព្រមព្រៀង

# ស្តីពី

# ទិដ្ឋភាពពាណិជ្ជកម្ម

# ទាក់ទងនឹង

# កម្មសិទ្ធិបញ្ញា

(កិច្ចព្រមព្រៀង TRIPS 1994)

**បណ្ណាល័យច្បាប់**-Law Library

www.facebook.com/lawslibraries

# កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្ម
# ទាក់ទងនឹងកម្មសិទ្ធិបញ្ញា
## (កិច្ចព្រមព្រៀង TRIPS 1994)

**ជំពូកទី១** : បទប្បញ្ញត្តិទូទៅនិងគោលការណ៍ជាមូលដ្ឋាន

**ជំពូកទី២** : បទដ្ឋានទាក់ទងនឹងអត្ថិភាព វិសាលភាព និងការប្រើប្រាស់សិទ្ធិកម្មសិទ្ធិបញ្ញា

១- សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

២-ម៉ាក

៣- ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

៤- គំនូរឧស្សាហកម្ម

៥-- ប្រកាសនីយបត្រតក្កកម្ម

៦- គំនូសបង្ហាញនៃសៀគ្វីបង្រួម

៧-កិច្ចការពារព័ត៌មានសម្ងាត់

៨- ការត្រួតពិនិត្យការអនុវត្តន៍ដែលផ្ទុយនឹងការប្រកួតប្រជែងក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណ

**ជំពូកទី៣** : ការអនុវត្តន៍សិទ្ធិកម្មសិទ្ធិបញ្ញា

១- កាតព្វកិច្ចទូទៅ

២- នីតិវិធីរដ្ឋប្បវេណីនិងរដ្ឋបាល និងវិធានការដោះស្រាយ

៣-វិធានការបណ្ដោះអាសន្ន

៤-លក្ខខណ្ឌពិសេសទាក់ទងនឹងវិធានការតាមមាត់ច្រកព្រំដែន

៥-នីតិវិធីព្រហ្មទណ្ឌ

**ជំពូកទី៤** : ការទទួលបាននិងការរក្សាសិទ្ធិកម្មសិទ្ធិបញ្ញា និងនីតិវិធីទាក់ទងនឹងភាគីដែលពាក់ព័ន្ធ

**ជំពូកទី៥** : ការបង្ការ និងការដោះស្រាយជម្លោះ

**ជំពូកទី៦** : បទប្បញ្ញត្តិអន្តរកាល

**ជំពូកទី៧** : បទប្បញ្ញត្តិស្តីពីស្ថាប័ន អវសានប្បញ្ញាត្តិ

សមាជិកទាំងឡាយៈ

ចេតនាដើម្បីកាត់បន្ថយការក្លែងបន្លំនិងឧបសគ្គចំពោះពាណិជ្ជកម្មអន្តរជាតិ និងពិចារណាលើភាពចាំបាច់ដើម្បីជម្រុញកិច្ចការពារសិទ្ធិកម្មសិទ្ធិបញ្ញាឱ្យមានប្រសិទ្ធភាពនិងគ្រប់គ្រាន់ ហើយដើម្បីធានាថាវិធានការនិងនីតិវិធីអនុវត្តសិទ្ធិកម្មសិទ្ធិបញ្ញា មិនក្លាយជារបាំងចំពោះពាណិជ្ជកម្មស្របច្បាប់

ដោយទទួលស្គាល់ ដើម្បីសម្រេចគោលបំណងនេះ តម្រូវការច្បាប់និងវិធានថ្មីដែលពាក់ព័ន្ធនឹងៈ

(ក) ភាពដែលអាចអនុវត្តបាននៃគោលការណ៍មូលដ្ឋានរបស់កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម ១៩៩៤ និងនៃកិច្ចព្រមព្រៀងឬអនុសញ្ញាកម្មសិទ្ធិបញ្ញាអន្តរជាតិទាំងឡាយ

(ខ) បទប្បញ្ញត្តិនៃបទដ្ឋានសមស្រប និងគោលការណ៍ដែលពាក់ព័ន្ធនឹង អត្ថិភាព វិសាលភាព និងការប្រើប្រាស់សិទ្ធិកម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងពាណិជ្ជកម្ម

(គ) បទប្បញ្ញត្តិនៃមធ្យោបាយដែលមានប្រសិទ្ធភាពនិងសបស្របសម្រាប់ការអនុវត្តន៍សិទ្ធិកម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងពាណិជ្ជកម្ម ដោយពិចារណាលើភាពផ្សេងគ្នាក្នុងប្រព័ន្ធច្បាប់ជាតិ

(ឃ)បទប្បញ្ញត្តិនៃនីតិវិធីដែលមានប្រសិទ្ធភាពនិងរហ័សសម្រាប់ទប់ស្កាត់និងដោះស្រាយវិវាទពហុភាគីរវាងរដ្ឋាភិបាល និង

(ង) បទប្បញ្ញត្តិអន្តរកាល ដែលមានបំណងឱ្យមានការចូលរួមពេញលេញក្នុងលទ្ធផលនៃការចរចារ

ដោយទទួលស្គាល់ភាពចាំបាច់នូវក្របខណ្ឌគោលការណ៍ ច្បាប់ និងវិធានពហុភាគីដែលទាក់ទងនឹងពាណិជ្ជកម្មអន្តរជាតិលើទំនិញល្មើស

ដោយទទួលស្គាល់ថា សិទ្ធិកម្មសិទ្ធិបញ្ញាជាសិទ្ធិឯកជន

ដោយទទួលស្គាល់គោលបំណងនៃគោលនយោបាយនៃប្រព័ន្ធជាតិ ចំពោះកិច្ចការពារកម្មសិទ្ធិបញ្ញា ដែលរួមទាំងគោលបំណងនៃការអភិវឌ្ឍន៍និងគោលបំណងបច្ចេកវិទ្យា

ដោយទទួលស្គាល់ផងដែរនូវតម្រូវការពិសេស នៃសមាជិកប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុត ចំពោះភាពដែលអាចបត់បែនបានជាអតិបរមាក្នុងការអនុវត្តន៍ច្បាប់និងបទបញ្ញាក្នុងស្រុក ដើម្បីឱ្យប្រទេសទាំងនេះអាចបង្កើតមូលដ្ឋានបច្ចេកវិទ្យាដែលរឹងមាំនិងអាចជឿទុកចិត្តបាន

ដោយសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការកាត់បន្ថយភាពតានតឹង ដោយសម្រេចពង្រឹងការប្តេជ្ញាចិត្ត ដើម្បីដោះស្រាយវិវាទស្តីពីបញ្ហាកម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងពាណិជ្ជកម្មតាមរយៈនីតិវិធីពហុភាគី

ចេតនាដើម្បីបង្កើតទំនាក់ទំនងដែលគាំទ្រគ្នាទៅវិញទៅមករវាងអង្គការពាណិជ្ជកម្មពិភពលោកនិងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (យោងក្នុងកិច្ចព្រមព្រៀងនេះជា WIPO) ក៏ដូចជាអង្គអន្តរជាតិផ្សេងទៀតដែលពាក់ព័ន្ធ

បានយល់ព្រមដូចខាងក្រោមៈ

# ជំពូកទី១

# បទប្បញ្ញត្តិទូទៅនិងគោលការណ៍ជាមូលដ្ឋាន

## មាត្រា១

## សារជាតិនិងវិសាលភាពនៃកាតព្វកិច្ច

១- សមាជិកទាំងឡាយត្រូវបង្កើតឱ្យមានអានុភាពចំពោះបទប្បញ្ញត្តិទាំងឡាយនៃកិច្ចព្រមព្រៀងនេះ។ សមាជិកទាំងឡាយអាចអនុវត្តក្នុងច្បាប់របស់ខ្លួននូវកិច្ចការពារដែលមានលក្ខណៈធំទូលាយជាងអ្វីដែលតម្រូវដោយកិច្ចព្រមព្រៀងនេះ ប៉ុន្តែមិនមែនជាកាតព្វកិច្ចបង្ខំទេ ឱ្យតែកិច្ចការពារនេះមិនផ្ទុយទៅនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង។ សមាជិកទាំងឡាយត្រូវមានសេរីភាពកំណត់វិធីសាស្ត្រសមស្រប ដើម្បីអនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ក្នុងប្រព័ន្ធច្បាប់និងការអនុវត្តន៍របស់ខ្លួន។

២- ក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ ពាក្យថា "កម្មសិទ្ធិបញ្ញា" សំដៅដល់ប្រភេទទាំងអស់នៃកម្មសិទ្ធិបញ្ញាដែលជាកម្មវត្ថុ នៃផ្នែកទី១រហូតដល់ផ្នែកទី៧ នៃជំពូកទី២។

៣- សមាជិកទាំងឡាយ ត្រូវផ្តល់ប្រព្រឹត្តិកម្មដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ចំពោះពលរដ្ឋនៃសមាជិកផ្សេងទៀត[១]។ ចំពោះកម្មសិទ្ធិបញ្ញាដែលពាក់ព័ន្ធ ពលរដ្ឋនៃសមាជិកផ្សេងទៀតមានន័យថា ជារូបវន្តបុគ្គលឬនីតិបុគ្គលទាំងឡាយ ដែលបំពេញតាមលក្ខណៈវិនិច្ឆ័យដើម្បីទទួលបានកិច្ចការពារ ដូចមានចែងក្នុងអនុសញ្ញាទីក្រុងប៉ារីស(១៩៦៧) អនុសញ្ញាទីក្រុង

[១][កំណត់សម្គាល់កិច្ចព្រមព្រៀងTRIPS] នៅពេលពាក្យ "ពលរដ្ឋ" ដែលមានយោងនៅក្នុងកិច្ចព្រមព្រៀងនេះ ពាក្យនេះមានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានទីលំនៅ ឬមានគ្រឹះស្ថានឧស្សាហកម្ម ឬពាណិជ្ជកម្មពិតប្រាកដ និងកំពុងដំណើរការ ក្នុងដែនដីគយនោះ ក្នុងករណីសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកជាដែនដីគយដាច់ដោយឡែកមួយ។

ប៉ែន (១៩៧១) អនុសញ្ញាទីក្រុងរ៉ូម និងសន្ធិសញ្ញាស្តីពីកម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងសៀគ្វីបង្រួម ប្រសិនបើ សមាជិកទាំងអស់នៃអង្គការពាណិជ្ជកម្មពិភពលោកជាសមាជិកនៃអនុសញ្ញាទាំងនេះ[២]។ សមាជិកណាមួយដែលប្រើប្រាស់លទ្ធភាពដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រា៥ ឬកថាខណ្ឌទី២នៃមាត្រា៦របស់អនុសញ្ញាទីក្រុងរ៉ូម ត្រូវជូនដំណឹង ដូចមានចែងក្នុងបទប្បញ្ញត្តិទាំងនេះ ទៅក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹង កម្មសិទ្ធិបញ្ញា (ក្រុមប្រឹក្សា TRIPS)។

## មាត្រា២

## អនុសញ្ញាស្តីពីកម្មសិទ្ធិបញ្ញា

១- ចំពោះជំពូកទី២ ជំពូកទី៣និងជំពូកទី៤ នៃកិច្ចព្រមព្រៀងនេះ សមាជិកទាំងឡាយត្រូវអនុវត្តតាមមាត្រា១ ដល់ មាត្រា១២ និងមាត្រា១៩ នៃអនុសញ្ញាទីក្រុងប៉ារីស(១៩៦៧)។

២- មិនត្រូវមានបទប្បញ្ញត្តិណាមួយនៅក្នុងជំពូកទី១ ដល់ជំពូកទី៤ នៃកិច្ចព្រមព្រៀងនេះ ចែងផ្ទុយនឹងកាតព្វកិច្ចដែលមានស្រាប់ ដែលសមាជិកទាំងឡាយត្រូវមានចំពោះគ្នាទៅវិញទៅមក តាមអនុសញ្ញាទីក្រុងប៉ារីស អនុសញ្ញាទីក្រុងប៉ែន អនុសញ្ញាទីក្រុងរ៉ូម និងសន្ធិសញ្ញាស្តីពីកម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងសៀគ្វីបង្រួម។

## មាត្រា៣

## ប្រព្រឹត្តិកម្មជាតិ

១- សមាជិកនីមួយៗ ត្រូវផ្តល់ឱ្យពលរដ្ឋនៃសមាជិកផ្សេងទៀតនូវប្រព្រឹត្តិកម្ម ដែលមិនត្រូវតិចជាងអ្វីដែលខ្លួនបានផ្តល់ចំពោះពលរដ្ឋរបស់ខ្លួនឡើយ ទាក់ទងនឹងកិច្ចការពារ[៣]កម្មសិទ្ធិបញ្ញា

---

[២] [ កំណត់សម្គាល់កិច្ចព្រមព្រៀង TRIPS ] ក្នុងកិច្ចព្រមព្រៀងនេះ "អនុសញ្ញាក្រុងប៉ារីស" សំដៅដល់អនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ហើយ "អនុសញ្ញាទីក្រុងប៉ារីស(១៩៦៧)" សំដៅដល់ ច្បាប់ទីក្រុងស្តុកហូមនៃអនុសញ្ញានេះ ចុះថ្ងៃទី១៤ខែកក្កដា ឆ្នាំ១៩៦៧។ "អនុសញ្ញាទីក្រុងប៉ែន" សំដៅដល់ អនុសញ្ញាទីក្រុងប៉ែនស្តីពីកិច្ចការពារស្នាដៃអក្សរសាស្ត្រ និងសិល្បៈ ហើយ "អនុសញ្ញាទីក្រុងប៉ែន (១៩៧១)" សំដៅដល់ច្បាប់ទីក្រុងប៉ារីសនៃអនុសញ្ញានេះ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ១៩៧១។ "អនុសញ្ញាទីក្រុងរ៉ូម" សំដៅដល់អនុសញ្ញាអន្តរជាតិស្តីពីកិច្ចការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយអនុមត់នៅទីក្រុងរ៉ូម ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៦១។ "សន្ធិសញ្ញាស្តីពីកម្មសិទ្ធិបញ្ញាទាក់ទងនឹងសៀគ្វីបង្រួម" (សន្ធិសញ្ញាIPIC) សំដៅដល់ សន្ធិសញ្ញាស្តីពីកម្មសិទ្ធិបញ្ញាទាក់ទងនឹងសៀគ្វីបង្រួម អនុម័តនៅទីក្រុងវ៉ាស៊ីនតោន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៨៩។ "កិច្ចព្រមព្រៀងស្តីពីអង្គការពាណិជ្ជកម្មពិភពលោក" សំដៅដល់ កិច្ចព្រមព្រៀងដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក។

[៣] ជាគោលបំណងនៃមាត្រា៣ និងមាត្រា៤ ពាក្យថា "ការពារ" ត្រូវរាប់បញ្ចូលនូវបញ្ហា ដែលប៉ះពាល់ដល់ អត្ថិភាព ការទទួលបាន វិសាលភាព ការរក្សា និងការអនុវត្តន៍កម្មសិទ្ធិបញ្ញា ក៏ដូចជាបញ្ហាដែលប៉ះពាល់ដល់ការប្រើប្រាស់កម្មសិទ្ធិបញ្ញាដែលបានលើកឡើងជាពិសេសក្នុងកិច្ចព្រមព្រៀងនេះ។

លើកលែងតែអញ្ញត្រកម្មដែលបានចែងផ្សេងៗគ្នា ក្នុងអនុសញ្ញាទីក្រុងប៉ារីស (១៩៦៧) អនុសញ្ញាទីក្រុងប៊ែន (១៩៧១) អនុសញ្ញាទីក្រុងរ៉ូម ឬសន្ធិសញ្ញាស្ដីពីកម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងសៀគ្វីបង្រួម។ ចំពោះអ្នកសម្ដែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយ កាតព្វកិច្ចនេះ អនុវត្តបានតែចំពោះសិទ្ធិដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះតែប៉ុណ្ណោះ។ សមាជិកណាមួយ ដែលប្រើប្រាស់លទ្ធភាពដូចមានចែងក្នុងមាត្រា៦នៃអនុសញ្ញាទីក្រុងប៊ែន (១៩៧១) ឬកថាខណ្ឌទី១(ខ)នៃមាត្រា១៦នៃអនុសញ្ញាទីក្រុងរ៉ូម ត្រូវជូនដំណឹង ដូចមានចែងក្នុងបទប្បញ្ញត្តិទាំងនេះ ទៅក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា(ក្រុមប្រឹក្សាTRIPS)។

២- សមាជិកទាំងឡាយអាចប្រើប្រាស់ការលើកលែងដែលបានអនុញ្ញាតដោយកថាខណ្ឌទី១ ដែលទាក់ទងនឹងនីតិវិធីតុលាការនិងនីតិវិធីរដ្ឋបាល រួមមានការកំណត់អាសយដ្ឋានសម្រាប់សេវាកម្មឬការតែងតាំងភ្នាក់ងារនៅក្នុងដែនយុត្តាធិការរបស់សមាជិកមួយ តែក្នុងករណីដែលការលើកលែងទាំងនោះមានភាពចាំបាច់ ដើម្បីធានាឱ្យមានភាពស្របគ្នាទៅនឹងច្បាប់និងបទបញ្ជាផ្សេងៗ ដែលមិនស្របទៅនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ហើយបើការអនុវត្តន៍ទាំងនោះមិនត្រូវបានធ្វើឡើងតាមរបៀបដែលបង្កើតជាការដាក់កម្រិតដោយបន្លំណាមួយ ចំពោះពាណិជ្ជ-កម្ម។

## មាត្រា៤
## ប្រព្រឹត្តិកម្មនៃប្រជាជាតិ ដែលទទួលការអនុគ្រោះបំផុត

ចំពោះកិច្ចការពារកម្មសិទ្ធិបញ្ញា ផលប្រយោជន៍ ការអនុគ្រោះ បុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិណាមួយដែលបានផ្ដល់ដោយសមាជិកមួយ ចំពោះពលរដ្ឋនៃប្រទេសផ្សេងទៀត ត្រូវតែផ្ដល់ឱ្យភ្លាមៗ និងគ្មានលក្ខខណ្ឌចំពោះពលរដ្ឋនៃសមាជិកផ្សេងទៀត។ ត្រូវបានលើកលែងពីកាតព្វកិច្ចនេះ គឺផលប្រយោជន៍ ការអនុគ្រោះ បុព្វសិទ្ធិ ឬអភ័យឯកសិទ្ធិណាមួយ ដែលបានផ្ដល់ដោយសមាជិកមួយៈ

ក- ដែលកើតចេញពីកិច្ចព្រមព្រៀងអន្តរជាតិស្ដីពីជំនួយផ្នែកយុត្តិធម៌ ឬការអនុវត្តន៍ច្បាប់ដែលមានលក្ខណៈទូទៅ ហើយដែលមិនបានកម្រិតដោយឡែកចំពោះកិច្ចការពារកម្មសិទ្ធិបញ្ញា។

ខ- ដែលត្រូវបានផ្ដល់ឱ្យ ដោយយោងតាមបទប្បញ្ញត្តិនៃអនុសញ្ញាទីក្រុងប៊ែន(១៩៧១) ឬអនុសញ្ញាទីក្រុងរ៉ូម ដែលបានអនុញ្ញាតឱ្យប្រព្រឹត្តិកម្មនោះ មានមុខងារមិនមែនជាប្រព្រឹត្តិកម្មជាតិ តែជាប្រព្រឹត្តិកម្មដែលត្រូវបានផ្ដល់ឱ្យនៅក្នុងប្រទេសមួយផ្សេងទៀត។

គ- ចំពោះសិទ្ធិអ្នកសម្តែង ផលិតករហ្វូណូក្រាម និងអង្គភាពទូរផ្សាយដែលមិនបានចែងក្នុងកិច្ចព្រមព្រៀងនេះ។

ឃ- ដែលកើតចេញមកពីកិច្ចព្រមព្រៀងអន្តរជាតិ ដែលទាក់ទងទៅនឹងកិច្ចការពារកម្មសិទ្ធិបញ្ញា ដែលបានចូលជាធរមានមុនពេលចូលជាធរមាននៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ឱ្យតែកិច្ចព្រមព្រៀងទាំងនេះ ត្រូវបានជូនដំណឹងទៅក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ហើយមិនបង្កើតជាការរើសអើងតាមអំពើចិត្តឬមិនសមហេតុផលប្រឆាំងនឹងពលរដ្ឋនៃសមាជិកផ្សេងទៀត ។

## មាត្រា៥

## កិច្ចព្រមព្រៀងពហុភាគី ស្តីពីការទទួលបាន ឬ ការរក្សាកិច្ចការពារ

កាតព្វកិច្ចដែលចែងក្នុងមាត្រា៣និងមាត្រា៤ មិនត្រូវអនុវត្តចំពោះនីតិវិធីទាំងឡាយ ដែលមានចែងក្នុងកិច្ចព្រមព្រៀងពហុភាគី ដែលចុះហត្ថលេខាក្រោមការឧបត្ថម្ភរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកទាក់ទងទៅនឹងការទទួលបាន ឬការរក្សាសិទ្ធិកម្មសិទ្ធិបញ្ញា។

## មាត្រា៦

## ការរលត់សិទ្ធិ

ក្នុងគោលបំណងដោះស្រាយវិវាទ តាមកិច្ចព្រមព្រៀងនេះ លើកលែងតែបទប្បញ្ញត្តិនៃមាត្រា៣និងមាត្រា៤ គ្មានបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ ត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយបញ្ហានៃការរលត់សិទ្ធិខាងកម្មសិទ្ធិបញ្ញា។

## មាត្រា៧

## គោលបំណង

កិច្ចការពារ និងការអនុវត្តន៍កម្មសិទ្ធិបញ្ញា គួរចូលរួមចំណែកដើម្បីលើកស្ទួយការច្នៃប្រឌិតនៃបច្ចេកវិជ្ជា និងការផ្ទេរ ព្រមទាំងការផ្សព្វផ្សាយបច្ចេកវិជ្ជា ដើម្បីប្រយោជន៍ទៅវិញទៅមករបស់ផលិតករនិងអ្នកប្រើប្រាស់ចំណេះដឹងផ្នែកបច្ចេកវិជ្ជា និងតាមរបៀបមួយដែលនាំឱ្យមាននូវសុខុមាលភាពសង្គមនិងសេដ្ឋកិច្ច ព្រមទាំងធានានូវតុល្យភាពរវាងសិទ្ធិនិងកាតព្វកិច្ច។

## មាត្រា៨

## គោលការណ៍

១- នៅក្នុងការបង្កើតនិងធ្វើវិសោធនកម្មច្បាប់និងបទបញ្ជារបស់ខ្លួន សមាជិកទាំងឡាយ

ត្រូវអនុម័តនូវវិធានការចាំបាច់ដើម្បីការពារសុខភាពសាធារណៈនិងអាហារូបត្ថម្ភ និងដើម្បីលើកស្ទួយផលប្រយោជន៍សាធារណៈក្នុងវិស័យដែលមានសារៈសំខាន់បំផុតចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនិងបច្ចេកវិជ្ជា ឱ្យតែវិធានការទាំងនេះស្របទៅនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

២- វិធានការសមរម្យ ឱ្យតែស្របទៅនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ អាចត្រូវការដើម្បីបង្ការការរំលោភបំពានកម្មសិទ្ធិបញ្ញាដោយម្ចាស់សិទ្ធិឬការអនុវត្តន៍ទាំងឡាយណា ដែលធ្វើឱ្យរាំងស្ទះដោយគ្មានហេតុផលចំពោះពាណិជ្ជកម្ម ឬធ្វើអោយជះឥទ្ធិពលអាក្រក់ដល់ការផ្ទេរជាអន្តរជាតិនូវបច្ចេកវិទ្យា។

## ជំពូកទី២
## បទដ្ឋានទាក់ទងនឹងអត្ថិភាព វិសាលភាព និងការប្រើប្រាស់សិទ្ធិកម្មសិទ្ធិបញ្ញា

### ផ្នែកទី១ : សិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល

#### មាត្រា៩
#### ទំនាក់ទំនងជាមួយអនុសញ្ញាទីក្រុងប៊ែន

១- សមាជិកទាំងឡាយត្រូវអនុលោមតាមមាត្រា១ដល់មាត្រា២១នៃអនុសញ្ញាទីក្រុងប៊ែន (១៩៧១)និងច្បាប់បន្ថែមរបស់អនុសញ្ញានេះ។ ប៉ុន្តែសមាជិកទាំងឡាយ គ្មានសិទ្ធិឬកាតព្វកិច្ចតាមកិច្ចព្រមព្រៀងនេះ ចំពោះសិទ្ធិដែលបានផ្តល់ឱ្យតាមមាត្រា៦ស្ទួន ឬសិទ្ធិផ្សេងទៀតដែលកើតចេញពីអនុសញ្ញានេះ។

២- សិទ្ធិអ្នកនិពន្ធ ត្រូវការពារចំពោះការសំដែងគំនិត ប៉ុន្តែមិនការពារចំពោះគំនិត នីតិវិធី របៀបប្រតិបត្តិការ ឬទស្សនៈគណិតវិទ្យា នោះឡើយ។

#### មាត្រា១០
#### កម្មវិធីកុំព្យូទ័រនិងការចងក្រងទិន្នន័យ

១- ទោះបីជានៅក្នុងទម្រង់ប្រភពដើម ឬមានភាពជាលេខកូដក្តី កម្មវិធីកុំព្យូទ័រត្រូវការពារជាស្នាដៃអក្សរសាស្ត្រ តាមអនុសញ្ញាទីក្រុងប៊ែន(១៩៧១)។

២- ការចងក្រងទិន្នន័យឬឯកសារផ្សេងទៀត ទោះបីជាស្ថិតក្រោមទំរង់ដែលម៉ាស៊ីនអាចអានបានឬទម្រង់ផ្សេងទៀត ដោយមូលហេតុនៃការជ្រើសរើស ឬ ការរៀបចំមាតិកា ដែលបង្កើតជាសមិទ្ធិផលខាងបញ្ញា ក៏ត្រូវការពារដែរ។ កិច្ចការពារនេះ មិនត្រូវធ្វើឡើងចំពោះទិន្នន័យ ឬឯកសារទេ ប៉ុន្តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអ្នកនិពន្ធនៃទិន្នន័យ ឬឯកសារទាំងនេះឡើយ ។

## មាត្រា១១

## សិទ្ធិជួល

យ៉ាងហោចណាស់ចំពោះកម្មវិធីកុំព្យូទ័រនិងស្នាដៃខ្សែភាពយន្ត សមាជិកត្រូវផ្តល់ឱ្យអ្នកនិពន្ធនិងអ្នកទទួលសិទ្ធិនូវសិទ្ធិអនុញ្ញាត ឬសិទ្ធិហាមឃាត់ការជួលលក្ខណៈពាណិជ្ជកម្មដល់សាធារណជននូវច្បាប់ដើមឬច្បាប់ចម្លងនៃស្នាដៃដែលការពារដោយសិទ្ធិអ្នកនិពន្ធ។ សមាជិកត្រូវបានលើកលែងពីកាតព្វកិច្ចនេះចំពោះស្នាដៃភាពយន្ត លើកលែងតែការជួលនេះធ្វើឱ្យរីកសាយភាយច្បាប់ចម្លងនៃស្នាដៃ ដែលធ្វើឱ្យខូចខាតផ្នែកសម្ភារៈចំពោះសិទ្ធិផ្តាច់មុខនៃការផលិតឡើងវិញដែលផ្តល់ឱ្យដោយសមាជិកនោះចំពោះអ្នកនិពន្ធនិងអ្នកទទួលសិទ្ធិ។ កាតព្វកិច្ចនេះមិនត្រូវអនុវត្តចំពោះការជួលកម្មវិធីកុំព្យូទ័រ ក្នុងករណីដែលកម្មវិធីនេះមិនមែនជាកម្មវត្ថុសំខាន់សម្រាប់ការដាក់ជួល។

## មាត្រា១២

## រយៈពេលនៃកិច្ចការពារ

រយៈពេលនៃកិច្ចការពារស្នាដៃមួយ ក្រៅពីស្នាដៃខាងថតរូបឬស្នាដៃសិល្បៈអនុវត្ត ដែលត្រូវគណនាលើមូលដ្ឋានក្រៅអំពីមួយជីវិតរបស់រូបវន្តបុគ្គលម្នាក់ រយៈពេលនេះ មិនត្រូវតិចជាង៥០(ហាសិប)ឆ្នាំ ដោយគិតចាប់ពីបញ្ចប់ឆ្នាំប្រតិទិននៃការបោះពុម្ពផ្សាយដែលបានអនុញ្ញាត។ បើសិនខកខានមិនបានបោះពុម្ពផ្សាយដែលបានអនុញ្ញាតនោះ ក្នុងអំឡុងពេល៥០(ហាសិប)ឆ្នាំចាប់ពីពេលបង្កើតស្នាដៃ ស្នាដៃនោះត្រូវការពារ រយៈពេល៥០(ហាសិន)ឆ្នាំ ដោយគិតចាប់ពីបញ្ចប់ឆ្នាំប្រតិទិននៃការបង្កើតស្នាដៃ។

## មាត្រា១៣

## ការកម្រិតសិទ្ធិ និង ការលើកលែង

សមាជិកទាំងឡាយ ត្រូវកំណត់ការកម្រិតឬការលើកលែង ចំពោះសិទ្ធិផ្តាច់មុខ ក្នុងករណីពិសេសមួយចំនួន ដែលមិនផ្ទុយនឹងការធ្វើអាជីវកម្មធម្មតាលើស្នាដៃ និងមិនធ្វើឱ្យប៉ះពាល់ដោយគ្មានហេតុផលដល់ផលប្រយោជន៍ស្របច្បាប់នៃម្ចាស់សិទ្ធិ។

## មាត្រា១៤

## កិច្ចការពារអ្នកសម្តែង ផលិតករហ្វូណូក្រាម (ការថតសម្លេង) និងអង្គភាពទូរផ្សាយ

១- ចំពោះការថតបញ្ចូលការសម្តែងក្នុងហ្វូណូក្រាម អ្នកសម្តែងមានលទ្ធភាពបង្ការសកម្មភាពដែលប្រព្រឹត្តិដោយគ្មានការអនុញ្ញាតិដូចជាៈ ការថតបញ្ចូលការសំដែងដែលមិនទាន់

បានថតបញ្ចូលនិងការផលិតឡើងវិញនៃការថតបញ្ចូលនេះ។ អ្នកសម្តែងក៏មានលទ្ធភាពបង្ការសកម្មភាពដែលប្រព្រឹត្តិដោយគ្មានការអនុញ្ញាតផងដែរដូចជា: ការផ្សាយដោយមធ្យោបាយគ្មានខ្សែ និងការផ្សព្វផ្សាយជាសាធារណៈនូវការសម្តែងផ្ទាល់។

២- ផលិតករហ្វូណូក្រាមមានសិទ្ធិអនុញ្ញាតឬហាមឃាត់ការផលិតឡើងវិញនូវហ្វូណូក្រាមដោយផ្ទាល់ឬដោយប្រយោល។

៣- អង្គភាពទូរផ្សាយមានសិទ្ធិហាមឃាត់សកម្មភាពទាំងឡាយដែលប្រព្រឹត្តិដោយគ្មានការអនុញ្ញាតដូចជា: ការថតបញ្ចូល ការផលិតឡើងវិញនូវការថតបញ្ចូលនិងការផ្សាយឡើងវិញដោយមធ្យោបាយគ្មានខ្សែនៃកម្មវិធីផ្សាយ ក៏ដូចជាការផ្សាយជាសាធារណៈនូវកម្មវិធីទូរទស្សន៍។ នៅពេលដែលសមាជិកទាំងឡាយមិនបានផ្តល់សិទ្ធិនេះទៅឱ្យអង្គភាពទូរផ្សាយទេ សមាជិកទាំងនេះត្រូវផ្តល់ឱ្យម្ចាស់សិទ្ធិអ្នកនិពន្ធ ចំពោះកម្មវិធីផ្សាយនូវលទ្ធភាពបង្ការសកម្មភាពទាំងឡាយខាងលើ លើកលែងតែអ្វីដែលមានចែងក្នុងបទប្បញ្ញត្តិនៃអនុសញ្ញាទីក្រុងប៊ែន(១៩៧១)។

៤- បទប្បញ្ញត្តិនៃមាត្រា១១ ដែលទាក់ទងនឹងកម្មវិធីកុំព្យូទ័រ ត្រូវអនុវត្តផងដែរចំពោះផលិតករហ្វូណូក្រាមនិងចំពោះម្ចាស់សិទ្ធិផ្សេងទៀតនៃហ្វូណូក្រាម ដូចបានកំណត់ក្នុងច្បាប់របស់សមាជិក។ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤ ប្រសិនបើសមាជិកមានជាធរមាននូវប្រព័ន្ធបែងចែកលាភការដោយសមភាព ចំពោះម្ចាស់សិទ្ធិដែលទាក់ទងនឹងការជួលហ្វូណូក្រាម សមាជិកនេះអាចរក្សាទុកនូវប្រព័ន្ធនេះ ឱ្យតែការជួលហ្វូណូក្រាមជាលក្ខណៈពាណិជ្ជកម្មមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិផ្តាច់មុខនៃការផលិតឡើងវិញរបស់ម្ចាស់សិទ្ធិ។

៥-រយៈពេលនៃកិច្ចការពារដែលមានតាមកិច្ចព្រមព្រៀងនេះចំពោះអ្នកសម្តែង និងផលិតករហ្វូណូក្រាម ត្រូវមានយ៉ាងហោចណាស់រហូតដល់បញ្ចប់រយៈពេល៥០(ហាសិប)ឆ្នាំ គិតចាប់ពីចុងឆ្នាំប្រតិទិននៃការថតឬការសម្តែង។ រយៈពេលនៃកិច្ចការពារ ដែលបានផ្តល់ឱ្យតាមកថាខណ្ឌទី៣ ត្រូវមានរយៈពេលយ៉ាងហោចណាស់២០(ម្ភៃ)ឆ្នាំគិតចាប់តាំងពីចុង ឆ្នាំប្រតិទិននៃការផ្សាយ។

៦- ចំពោះសិទ្ធិទាំងឡាយដែលផ្តល់ឱ្យតាមកថាខណ្ឌទី១ ទី២និងទី៣ សមាជិកណាមួយអាចចែងអំពីលក្ខខណ្ឌ ការកម្រិត ការលើកលែងនិងខដាក់លក្ខខណ្ឌ ត្រឹមកម្រិតដែលអនុញ្ញាតដោយអនុសញ្ញាទីក្រុងរ៉ូម។ ប៉ុន្តែបទប្បញ្ញត្តិ មាត្រា១៨នៃអនុសញ្ញាទីក្រុងប៊ែន(១៩៧១) ត្រូវអនុវត្តដូចគ្នា ប៉ុន្តែអាចកែប្រែតាមការចាំបាច់ ចំពោះសិទ្ធិអ្នកសម្តែង និងផលិតករហ្វូណូក្រាម។

## ផ្នែកទី២ : ម៉ាក

### មាត្រា១៥

### កម្មវត្ថុដែលអាចការពារបាន

១- សញ្ញាណាមួយឬបង្គុំណាមួយនៃសញ្ញា ដែលអាចញែកដាច់ពីគ្នានូវទំនិញឬសេវារបស់សហគ្រាសមួយ ពីទំនិញឬសេវារបស់សហគ្រាសផ្សេងទៀត អាចបង្កើតបានជាម៉ាក។ សញ្ញាទាំងនេះ ជាពិសេស ពាក្យដែលរួមមាន ឈ្មោះបុគ្គល អក្សរ លេខ សមាសធាតុជារូបភាពនិងបង្គុំនៃពណ៌ ព្រមទាំងបង្គុំនៃសញ្ញាទាំងនេះ អាចត្រូវបានទទួលឱ្យចុះបញ្ជីជាម៉ាក។ នៅពេលដែលសញ្ញាគ្មានសមត្ថភាពញែកឱ្យដាច់ពីគ្នានូវទំនិញឬសេវាដែលពាក់ព័ន្ធ សមាជិកទាំងឡាយអាចចុះបញ្ជីបានអាស្រ័យដោយភាពញែកដាច់ពីគ្នា ដែលទទួលបានតាមរយៈការប្រើប្រាស់។ ជាលក្ខខណ្ឌនៃការចុះបញ្ជី សមាជិកទាំងឡាយអាចទាមទារឱ្យសញ្ញានោះជាសញ្ញាដែលមើលឃើញ។

២- កថាខណ្ឌទី១ខាងលើ មិនត្រូវយល់ថាជាការរាំងសមាជិកណាមួយ មិនឱ្យបដិសេធការចុះបញ្ជីម៉ាកដោយផ្អែកលើមូលដ្ឋានផ្សេងទៀតឡើយ ឱ្យតែមូលដ្ឋានទាំងនេះមិនផ្ទុយនឹងបទប្បញ្ញត្តិនៃអនុសញ្ញាទីក្រុងប៉ារីស(១៩៦៧)។

៣- សមាជិកទាំងឡាយអាចបង្កើតភាពដែលអាចចុះបញ្ជីបាន ដោយផ្អែកលើការប្រើប្រាស់។ ប៉ុន្តែ ការប្រើប្រាស់ជាក់ស្តែងនៃម៉ាក មិនត្រូវជាលក្ខខណ្ឌ សម្រាប់ការដាក់ពាក្យសុំចុះបញ្ជីឡើយ។ ពាក្យសុំចុះបញ្ជីមិនត្រូវបដិសេធ ដោយផ្អែកតែទៅលើមូលដ្ឋានដែលថាគ្មានការប្រើប្រាស់ដោយចេតនាមុនផុតរយៈពេល៣(បី)ឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទនៃពាក្យសុំចុះបញ្ជី។

៤- សារជាតិនៃទំនិញឬសេវា ដែលត្រូវបំពាក់ម៉ាក មិនត្រូវបង្កើតជាឧបសគ្គណាមួយដើម្បីចុះបញ្ជីម៉ាកឡើយ។

៥- សមាជិកទាំងឡាយត្រូវបោះពុម្ពផ្សាយម៉ាកនីមួយៗមុនចុះបញ្ជីឬក្រោយចុះបញ្ជីភ្លាម ហើយត្រូវផ្តល់ឱកាសសមរម្យដើម្បីប្តឹងបដិសេធការចុះបញ្ជី។ ជាងនេះទៅទៀត សមាជិកទាំងឡាយ អាចផ្តល់ឱកាសឱ្យប្តឹងជំទាស់ចំពោះការចុះបញ្ជីម៉ាក ។

### មាត្រា១៦

### សិទ្ធិដែលកើតឡើងពីការចុះបញ្ជីម៉ាក

១- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច មានសិទ្ធិផ្តាច់មុខដើម្បីហាមតតិយជន ដោយគ្មានការយល់ព្រមពីម្ចាស់ម៉ាក មិនឱ្យប្រើប្រាស់ក្នុងចរន្តពាណិជ្ជកម្មនូវសញ្ញាដែលដូចឬប្រហាក់

ប្រហែលគ្នា ចំពោះទំនិញឬសេវាដែលដូចឬប្រហាក់ប្រហែលគ្នាទៅនឹងសញ្ញាដែលបានចុះបញ្ជីជាម៉ាកហើយដែលការប្រើប្រាស់នេះនឹងបណ្តាលឱ្យមានការភ័ន្តច្រឡំ។ ក្នុងករណីនៃការប្រើប្រាស់សញ្ញាដែលដូចគ្នាចំពោះទំនិញឬសេវាដែលដូចគ្នា ភាពដូចគ្នាដែលអាចបង្កើតឱ្យមានការភ័ន្តច្រឡំ ត្រូវបានសន្មត។សិទ្ធិដែលបានរៀបរាប់ខាងលើ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិដែលមានពីមុនស្រាប់ ឬមិនត្រូវធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពនៃសមាជិកទាំងឡាយ ក្នុងការបង្កើតសិទ្ធិនានា ដោយឈរលើមូលដ្ឋាននៃការប្រើប្រាស់ឡើយ។

២- មាត្រា៦ស្ទួននៃអនុសញ្ញាទីក្រុងប៉ារីស(១៩៦៧) ត្រូវអនុវត្តដូចគ្នាប៉ុន្តែអាចកែប្រែតាមការចាំបាច់ចំពោះសេវា។ ដើម្បីកំណត់ថាម៉ាកមួយជាម៉ាកល្បី សមាជិកទាំងឡាយត្រូវពិចារណាលើការយល់ដឹង អំពីម៉ាករបស់សាធារណៈជនចំពោះវិស័យដែលពាក់ព័ន្ធ ដោយរួមបញ្ចូលទាំងការយល់ដឹងនៅក្នុងសមាជិកពាក់ព័ន្ធ ដែលបានទទួលពីលទ្ធផលនៃការផ្សព្វផ្សាយនៃម៉ាកនោះ។

៣- មាត្រា៦ស្ទួននៃអនុសញ្ញាទីក្រុងប៉ារីស(១៩៦៧) ត្រូវអនុវត្តដូចគ្នាប៉ុន្តែអាចកែប្រែ តាមការចាំបាច់ចំពោះទំនិញឬសេវា ដែលមិនប្រហាក់ប្រហែលទៅនឹងទំនិញឬសេវានៃម៉ាកដែលបានចុះបញ្ជីរួច ឱ្យតែការប្រើប្រាស់ម៉ាកចំពោះទំនិញឬសេវាទាំងនេះ អាចបង្ហាញនូវទំនាក់ទំនងរវាងទំនិញឬសេវាជាមួយនឹងម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ហើយឱ្យតែប្រយោជន៍របស់ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច អាចត្រូវខូចខាតដោយការប្រើប្រាស់នោះ។

## មាត្រា១៧
## ការលើកលែង

សមាជិកទាំងឡាយអាចចែងឱ្យមានការលើកលែងដែលមានកម្រិត ចំពោះសិទ្ធិដែលបានផ្តល់ឱ្យដោយម៉ាក ដូចជា ការប្រើប្រាស់សមរម្យនូវពាក្យពេចន៍ពណ៌នា ឱ្យតែការលើកលែងនេះគិតគូរដល់ប្រយោជន៍ស្របច្បាប់របស់ម្ចាស់ម៉ាកនិងរបស់តតិយជន។

## មាត្រា១៨
## រយៈពេលនៃកិច្ចការពារ

ការចុះបញ្ជីដំបូងនិងការចុះបញ្ជីសារជាថ្មីនៃម៉ាក ត្រូវមានរយៈពេលមិនតិចជាង៧(ប្រាំពីរ)ឆ្នាំ។ ការចុះបញ្ជីម៉ាកអាចធ្វើសារជាថ្មីបានដោយគ្មានកំណត់។

## មាត្រា១៩
## លក្ខខណ្ឌតម្រូវនៃការប្រើប្រាស់

១-បើការប្រើប្រាស់ត្រូវតម្រូវដើម្បីរក្សាការចុះបញ្ជី ការចុះបញ្ជីអាចត្រូវលុបចោលតែបន្ទាប់ពីរយៈពេលយ៉ាងហោចណាស់៣(បី)ឆ្នាំជាប់គ្នារហូតនៃការមិនប្រើប្រាស់ លើកលែងតែមានហេតុផលសមរម្យដោយសំអាងលើឧបសគ្គនានានៃការប្រើប្រាស់ ដែលលើកឡើងដោយម្ចាស់ម៉ាក។ ស្ថានភាពនានាដែលកើតឡើងក្រៅពីឆន្ទៈរបស់ម្ចាស់ម៉ាកដែលជាឧបសគ្គក្នុងការប្រើប្រាស់ម៉ាក ដូចជាការរិតត្បិតការនាំចូលឬលក្ខខណ្ឌតម្រូវផ្សេងទៀត របស់រដ្ឋាភិបាលចំពោះទំនិញឬសេវាដែលបានការពារដោយម៉ាក ត្រូវទទួលស្គាល់ថាជាហេតុផលសមរម្យចំពោះការមិនប្រើប្រាស់នេះ។

២- នៅពេលមានការត្រួតពិនិត្យពីម្ចាស់ម៉ាក ការប្រើប្រាស់ម៉ាកមួយដោយបុគ្គលផ្សេងទៀត ត្រូវទទួលស្គាល់ថាជាការប្រើប្រាស់ម៉ាកក្នុងគោលបំណងដើម្បីរក្សាការចុះបញ្ជី។

## មាត្រា២០

## លក្ខខណ្ឌតម្រូវផ្សេងទៀត

ការប្រើប្រាស់ម៉ាកក្នុងចរន្តពាណិជ្ជកម្ម មិនត្រូវបង្កការលំបាកដោយគ្មានហេតុផលដោយលក្ខខណ្ឌតម្រូវពិសេសនានា ដូចជា ការប្រើប្រាស់ជាមួយម៉ាកផ្សេង ការប្រើប្រាស់ក្រោមទម្រង់ពិសេស ឬការប្រើប្រាស់ក្នុងលក្ខណៈដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពនៃការញែកដាច់ពីគ្នានូវទំនិញឬសេវារបស់សហគ្រាសមួយ ពីទំនិញឬសេវារបស់សហគ្រាសផ្សេងទៀត។ ប្រការនេះមិនច្រានចោលលក្ខខណ្ឌតម្រូវ ដែលចែងអំពីការប្រើប្រាស់ម៉ាកសម្គាល់សហគ្រាសផលិតទំនិញឬសេវា ប៉ុន្តែគ្មានទំនាក់ទំនងរវាងគ្នា ជាមួយនឹងម៉ាកដែលញែកដាច់ពីគ្នានូវទំនិញឬសេវាជាក់លាក់របស់សហគ្រាសនេះ ។

## មាត្រា២១

## ការផ្តល់អាជ្ញាប័ណ្ណនិងការផ្ទេរសិទ្ធិ

សមាជិកទាំងឡាយអាចកំណត់លក្ខខណ្ឌចំពោះការផ្តល់អាជ្ញាប័ណ្ណ និងការផ្ទេរសិទ្ធិម៉ាកដោយត្រូវយល់ថាអាជ្ញាប័ណ្ណបញ្ជាចំពោះម៉ាកមិនត្រូវបានអនុញ្ញាតឡើយ ហើយម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចមានសិទ្ធិផ្ទេរម៉ាកដោយមានឬគ្មានការផ្ទេរអាជីវកម្មដែលប្រើប្រាស់ម៉ាកនោះ។

# ផ្នែកទី៣ : ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

## មាត្រា២២

## កិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

១- ក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសំដៅដល់ការ

ចង្អុលបង្ហាញដែលសម្គាល់ទំនិញមួយថាមានប្រភពក្នុងដែនដីនៃសមាជិកណាមួយឬតំបន់ ឬទីតាំងណាមួយនៃដែនដីនេះ ដែលមានគុណភាពជាក់លាក់ កិត្តិស័ព្ទ ឬ ចារិកលក្ខណៈផ្សេងទៀតនៃទំនិញ ដែលកើតចេញជាពិសេសពីប្រភពភូមិសាស្ត្រនោះ។

២- ចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ សមាជិកទាំងឡាយត្រូវផ្ដល់មធ្យោបាយតាមផ្លូវច្បាប់សម្រាប់ភាគីដែលមានប្រយោជន៍ដើម្បីបង្ការកុំឱ្យមាន :

ក- ការប្រើប្រាស់ដោយមធ្យោបាយណាមួយក្នុង ការរចនា ឬការបង្ហាញទំនិញ ដែលចង្អុលបង្ហាញ ឬនាំឱ្យគេយល់ថា ទំនិញនោះ មានប្រភពពីតំបន់ភូមិសាស្ត្រមួយ ក្រៅពីទីកន្លែងពិតប្រាកដនៃប្រភព ដែលនាំឱ្យសាធារណៈជនភ័ន្តច្រឡំអំពីប្រភពភូមិសាស្ត្រនៃទំនិញ។

ខ- ការប្រើប្រាស់ណាមួយ ដែលបង្កើតជាអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ តាមខ្លឹមសារនៃមាត្រា១០ស្ទួន នៃអនុសញ្ញាទីក្រុងប៉ារីស(១៩៦៧)។

៣- តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន បើច្បាប់អនុញ្ញាតឬតាមសំណើរបស់ភាគីដែលមានប្រយោជន៍ សមាជិកណាមួយអាចបដិសេធឬធ្វើមោឃភាពការចុះម៉ាក ដែលមានឬដែលបង្កើតពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ចំពោះទំនិញដែលគ្មានប្រភពពីដែនដីដែលបានចង្អុលបង្ហាញ បើការប្រើប្រាស់ការចង្អុលបង្ហាញរបស់ម៉ាកចំពោះទំនិញទាំងនេះក្នុងសមាជិកនោះ ធ្វើឱ្យសាធារណៈជនភ័ន្តច្រឡំអំពីទីកន្លែងពិតប្រាកដនៃប្រភព។

៤- កិច្ចការពារក្នុងកថាខណ្ឌទី១ ទី២ និងទី៣ អាចអនុវត្តបាន ប្រឆាំងនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលធ្វើឱ្យសាធារណជនយល់ខុសថា ទំនិញមានប្រភពពីដែនដីមួយផ្សេងទៀត ទោះបីជាដែនដី តំបន់ ឬទីតាំងដែលជាប្រភពនៃទំនិញមានពិតប្រាកដក៏ដោយ។

## មាត្រា២៣

## កិច្ចការពារបន្ថែមចំពោះម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសម្រាប់ស្រាទំពាំងបាយជូរនិងគ្រឿងស្រវឹង

១- សមាជិកនីមួយៗត្រូវផ្ដល់នូវមធ្យោបាយតាមផ្លូវច្បាប់សម្រាប់ភាគីដែលមានប្រយោជន៍ដើម្បីបង្ការកុំឱ្យមានការប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលសម្គាល់ស្រាទំពាំងបាយជូរចំពោះស្រាទំពាំងបាយជូរទាំងឡាយណាដែលគ្មានប្រភពពីទីកន្លែងដែលបានចង្អុលបង្ហាញដោយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះ ឬសម្គាល់គ្រឿងស្រវឹងចំពោះគ្រឿងស្រវឹងទាំងឡាយណា ដែលគ្មានប្រភពពីទីកន្លែងដែលបានចង្អុលបង្ហាញដោយម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះ ទោះបីបើប្រភពពិតប្រាកដនៃទំនិញត្រូវបានចង្អុលបង្ហាញ ឬម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបានប្រើប្រាស់ក្នុងការបកប្រែឬដែលអមដោយពាក្យនានា ដូចជា "ជំពូក" "ប្រភេទ" "រចនាបទ" "ការ

ត្រាប់តាម"ឬ"ពាក្យផ្សេងៗទៀតដែលមានលក្ខណៈប្រហាក់ប្រហែល[៥]"។

២- ការចុះបញ្ជីម៉ាកសម្រាប់ស្រាទំពាំងបាយជូរដែលមានឬដែលបង្កើតពីម៉ាកសម្គាល់ភូមិ-សាស្រ្តទំនិញ ដែលសម្គាល់ស្រាទំពាំងបាយជូរ ឬការចុះបញ្ជីម៉ាកសម្រាប់គ្រឿងស្រវឹង ដែលមានឬដែលបង្កើតពីម៉ាកសម្គាល់ភូមិសាស្រ្តទំនិញ ដែលសម្គាល់គ្រឿងស្រវឹង ត្រូវបដិសេធ ឬត្រូវធ្វើមោឃភាពតាមគំនិតផ្តួចផ្តើមរបស់ខ្លួន បើច្បាប់នៃសមាជិកអនុញ្ញាត ឬតាមសំណើរបស់ភាគីដែលមានប្រយោជន៍ ចំពោះស្រាទំពាំងបាយជូរឬគ្រឿងស្រវឹងណាដែលមិនចេញពីប្រភពនេះ។

៣- ត្រូវការពារម៉ាកនីមួយៗ ក្នុងករណីដែលម៉ាកសម្គាល់ភូមិសាស្រ្តទំនិញទាំងឡាយណាមានសូរស័ព្ទដូចគ្នាចំពោះស្រាទំពាំងបាយជូរ លើកលែងតែបទប្បញ្ញត្តិកថាខណ្ឌទី៤នៃមាត្រា២២ ។ សមាជិកនីមួយៗ ត្រូវកំណត់លក្ខខណ្ឌអនុវត្ត ចំពោះភាពខុសគ្នានៃម៉ាកដែលមានសូរស័ព្ទដូចគ្នា ដោយពិចារណាទៅលើភាពចាំបាច់ដើម្បីធានាឱ្យមានប្រព្រឹត្តិកម្មដោយសមធម៌ ចំពោះផលិតករដែលពាក់ព័ន្ធ និងដើម្បីធានាថា អតិថិជនមិនភ័ន្តច្រឡំ។

៤- ដើម្បីសម្រួលដល់កិច្ចការពារម៉ាកសម្គាល់ភូមិសាស្រ្តទំនិញចំពោះស្រាទំពាំងបាយជូរ ការចរចាត្រូវធ្វើឡើងក្នុងក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ចំពោះការបង្កើតប្រព័ន្ធពហុភាគីនៃការជូនដំណឹងនិងការចុះបញ្ជី ម៉ាកសម្គាល់ភូមិសាស្រ្តទំនិញនៃស្រាទំពាំងបាយជូរ ដែលអាចទទួលបានកិច្ចការពារនៅក្នុងសមាជិកទាំងឡាយណា ដែលបានចូលរួមក្នុងប្រព័ន្ធនេះ។

## មាត្រា២៤
## ការចរចាជាអន្តរជាតិ ការលើកលែង

១- សមាជិកទាំងឡាយយល់ព្រមចូលរួមចរចាសំដៅបង្កើនកិច្ចការពារម៉ាកសម្គាល់ភូមិសាស្រ្តទំនិញនីមួយៗ តាមមាត្រា២៣។ បទប្បញ្ញត្តិទាំងឡាយនៃកថាខណ្ឌទី៤ដល់ទី៨ខាងក្រោម មិនត្រូវប្រើប្រាស់ដោយសមាជិកណាមួយដើម្បីបដិសេធមិនព្រមចរចារឬបង្កើតកិច្ចព្រមព្រៀងទ្វេភាគីឬពហុភាគីឡើយ។ ក្នុងបរិបទនៃការចរចានេះ សមាជិកទាំងឡាយត្រូវមានឆន្ទៈពិចារណាលើការអនុវត្តន៍បន្តនូវបទប្បញ្ញត្តិទាំងនេះ ចំពោះម៉ាកសម្គាល់ភូមិសាស្រ្តទំនិញនីមួយៗ ហើយការប្រើប្រាស់ម៉ាកនេះ ជាកម្មវត្ថុនៃការចរចា។

២- ក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញាត្រូវត្រួតពិនិត្យឡើងវិញការអនុវត្តន៍បទប្បញ្ញត្តិនៃផ្នែកនេះ។ ការត្រួតពិនិត្យឡើងវិញជាដំបូង ត្រូវធ្វើឡើងក្នុងអំឡុង

---

[៥] [កំណត់សម្គាល់ក្នុងកិច្ចព្រមព្រៀងTRIPS] ថ្វីបើមានឃ្លាទីមួយនៃមាត្រា៤២ក៏ដោយ ចំពោះកាតព្វកិច្ចទាំងនេះ សមាជិកទាំងឡាយអាចចែងឱ្យមានការអនុវត្តន៍ដោយវិធានការរដ្ឋបាល។

ពេល២(ពីរ)ឆ្នាំ បន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក។ បញ្ហាណាមួយដែលប៉ះពាល់ដល់ការគោរពកាតព្វកិច្ចទាំងឡាយតាមបទប្បញ្ញត្តិទាំង-នេះអាចត្រូវស្នើឡើងទៅក្រុមប្រឹក្សានេះ។ តាមសំណើពីសមាជិកណាមួយក្រុមប្រឹក្សានេះ ត្រូវពិគ្រោះយោបល់ជាមួយសមាជិកណាមួយឬសមាជិកទាំងឡាយចំពោះបញ្ហាណា ដែលមិនអាចរកដំណោះស្រាយគួរជាទីពេញចិត្ត តាមរយៈការពិគ្រោះយោបល់ទ្វេភាគីឬពហុភាគីរវាងសមាជិកទាំងឡាយដែលពាក់ព័ន្ធ។ ក្រុមប្រឹក្សាត្រូវចាត់វិធានការដូចដែលបានព្រមព្រៀង ដើម្បីសម្រួលការប្រព្រឹត្តិទៅនៃផ្នែកនេះនិងដើម្បីសម្រេចគោលបំណងនៃផ្នែកនេះ ។

៣- ក្នុងការអនុវត្តន៍ផ្នែកនេះ សមាជិកមិនត្រូវបន្ថយកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដែលមានរួចហើយក្នុប្រទេសជាសមាជិក មុនកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។

៤- បទប្បញ្ញត្តិនៃផ្នែកនេះ មិនតម្រូវឱ្យសមាជិកណាមួយរារាំងការប្រើប្រាស់បន្ត ឬប្រហាក់ប្រហែលនូវម៉ាកសម្គាល់ភូមិសាស្ត្រទំនិញដោយឡែកណាមួយរបស់សមាជិកផ្សេងទៀតដែលសម្គាល់ស្រាទំពាំងបាយជូរ ឬគ្រឿងស្រវឹងចំពោះទំនិញឬសេវា ដោយពលរដ្ឋឬនិវេសនជនណាមួយដែលបានប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនោះជាបន្តបន្ទាប់ ចំពោះទំនិញឬសេវាដែលដូចគ្នាឬពាក់ព័ន្ធគ្នានៅក្នុងដែនដីនៃសមាជិកនោះក្នុងរយៈពេល(ក)យ៉ាងហោចណាស់ ១០(ដប់)ឆ្នាំមុនថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤ ឬ (ខ) បានប្រើប្រាស់ដោយសុច្ចរិតមុនកាលបរិច្ឆេទនេះ។

៥- ករណីម៉ាកត្រូវបានដាក់ពាក្យស្នើសុំឬត្រូវបានចុះបញ្ជីដោយសុច្ចរិត ឬករណីសិទ្ធិលើម៉ាកដែលទទួលបានតាមរយៈការប្រើប្រាស់ដោយសុច្ចរិត :

ក- មុនកាលបរិច្ឆេទនៃការអនុវត្តន៍បទប្បញ្ញត្តិទាំងនេះក្នុងប្រទេសជាសមាជិកដូចកំណត់ក្នុងជំពូកទី៦ ឬ

ខ- មុនម៉ាកសម្គាល់ភូមិសាស្ត្រទំនិញត្រូវបានការពារក្នុងប្រទេសនៃប្រភព វិធានការដែលបានអនុម័តយកដើម្បីអនុវត្តផ្នែកនេះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ភាពដែលអាចទទួលបានឬសុពលភាពនៃការចុះបញ្ជីម៉ាកឬសិទ្ធិប្រើប្រាស់ម៉ាក លើមូលដ្ឋានថា ម៉ាកនេះដូចឬប្រហាក់ប្រហែលទៅនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។

៦-ក្នុងផ្នែកនេះមិនតម្រូវឱ្យសមាជិកអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់សមាជិកណាមួយផ្សេងទៀតចំពោះទំនិញឬសេវាដែលពាក់ម៉ាកពាក់ព័ន្ធដូចគ្នា នឹង

ពាក្យពេចន៍ធម្មតាក្នុងភាសាទូទៅ ដូចជាឈ្មោះទូទៅសម្រាប់ទំនិញឬសេវាក្នុងដែនដីនៃសមាជិកនោះ។ ក្នុងផ្នែកនេះមិនតម្រូវឱ្យសមាជិកអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់សមាជិកណាមួយផ្សេងទៀតចំពោះផលិតផលស្រាទំពាំងបាយជូរដែលពាក់ម៉ាកពាក់ព័ន្ធដូចគ្នានឹងឈ្មោះជាទូទៅនៃប្រភេទទំពាំងបាយជូរដែលមានស្រាប់ក្នុងដែនដីនៃសមាជិកនោះចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។

៧- សមាជិកអាចចែងថា ការលើកឡើងសំណើណាមួយក្នុងផ្នែកនេះពាក់ព័ន្ធនឹងការប្រើប្រាស់ឬការចុះបញ្ជីម៉ាក ត្រូវធ្វើឡើងក្នុងរយៈពេល៥(ប្រាំ)ឆ្នាំបន្ទាប់ពីមានការប្រើប្រាស់ដែលធ្វើឱ្យខូចប្រយោជន៍ដល់ម៉ាកដែលបានការពារ ត្រូវបានដឹងជាទូទៅក្នុងប្រទេសជាសមាជិកនោះ ឬត្រូវធ្វើឡើងបន្ទាប់ពីកាលបរិច្ឆេទចុះបញ្ជីម៉ាក ក្នុងប្រទេសជាសមាជិកនោះ ឱ្យតែម៉ាកនេះត្រូវបានបោះពុម្ពផ្សាយត្រឹមកាលបរិច្ឆេទនេះ ប្រសិនបើកាលបរិច្ឆេទនេះកើតឡើងមុនកាលបរិច្ឆេទនៃការប្រើប្រាស់ដែលធ្វើឱ្យខូចប្រយោជន៍ ត្រូវបានដឹងជាទូទៅក្នុងប្រទេសជាសមាជិកនោះហើយ ឱ្យតែម៉ាកសម្គាល់ភូមិសាស្ត្រទំនិញនេះ មិនត្រូវបានប្រើប្រាស់ឬចុះបញ្ជីដោយចេតនាទុច្ចរិត។

៨- បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិបុគ្គលណាមួយ ក្នុងការប្រើប្រាស់ក្នុងចរន្តពាណិជ្ជកម្មនូវឈ្មោះបុគ្គលនោះឬឈ្មោះបុព្វជននៃបុគ្គលនោះ ក្នុងអាជីវកម្ម លើកលែងតែឈ្មោះនោះត្រូវបានប្រើប្រាស់ ធ្វើឱ្យសាធារណៈជនភ័ន្តច្រឡំ។

៩- កិច្ចព្រមព្រៀងនេះ គ្មានកាតព្វកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ដែលមិនបានការពារឬបញ្ឈប់កិច្ចការពារក្នុងប្រទេសនៃប្រភព ឬលែងប្រើប្រាស់ក្នុងប្រទេសនោះ។

## ផ្នែកទី៤ : គំនូរឧស្សាហកម្ម

### មាត្រា២៥

### លក្ខខណ្ឌតម្រូវដើម្បីការពារ

១- សមាជិកទាំងឡាយត្រូវចែងពីកិច្ចការពារគំនូរឧស្សាហកម្មដែលបានបង្កើតឡើងដោយឯករាជ្យហើយដែលមានលក្ខណៈថ្មីឬដើម ។ សមាជិកទាំងឡាយ អាចចែងថា គំនូរឧស្សាហកម្មដែលគ្មានលក្ខណៈថ្មីឬដើម ប្រសិនគំនូរនេះមិនខុសប្លែកខ្លាំងពីគំនូរដែលបានស្គាល់ឬបង្គុំធាតុនៃគំនូរដែលបានស្គាល់ ។ សមាជិកទាំងឡាយអាចចែងថា កិច្ចការពារនេះមិនលាតសន្ធឹងដល់គំនូរ ដែលបានបង្កើតជាពិសេសក្នុងគោលបំណងបច្ចេកទេសឬដំណើរការ។

២- សមាជិកនីមួយៗ ត្រូវធានាថា លក្ខខណ្ឌតម្រូវដើម្បីធានាការពារគំនូរផ្នែកវាយន-

ភ័ណ្ឌ ដែលពាក់ព័ន្ធដោយឡែកចំពោះតម្លៃ ការត្រួតពិនិត្យឬការបោះពុម្ពផ្សាយ ដែលមិនធ្វើឱ្យប៉ះពាល់ដោយគ្មានហេតុផលសមរម្យចំពោះឱកាសក្នុងការស្នើសុំ និងទទួលបានកិច្ចការពារ។ សមាជិកទាំងឡាយមានសេរីភាពក្នុងការបំពេញកាតព្វកិច្ចនេះ តាមរយៈច្បាប់ស្តីពីគំនូរឧស្សាហ-កម្ម ឬតាមរយៈច្បាប់សិទ្ធិអ្នកនិពន្ធ។

## មាត្រា២៦

## កិច្ចការពារ

១- ម្ចាស់គំនូរឧស្សាហកម្មដែលបានការពារ មានសិទ្ធិហាមឃាត់តតិយជនដោយគ្មានការអនុញ្ញាតពីម្ចាស់ មិនឱ្យផលិត លក់ ឬនាំចូលទំនិញដែលប្រើប្រាស់ឬបង្កើតដោយគំនូរឧស្សាហកម្ម ជាការចម្លង ឬការចម្លងផ្នែកសំខាន់នៃគំនូរដែលបានការពារ នៅពេលដែលសកម្មភាពទាំងនេះធ្វើឡើងក្នុងគោលបំណងពាណិជ្ជកម្ម ។

២- សមាជិកទាំងឡាយអាចចែងឱ្យមានការលើកលែងដែលមានកម្រិតចំពោះកិច្ចការពារគំនូរឧស្សាហកម្ម ឱ្យតែ ការលើកលែងនេះមិនធ្វើឱ្យប៉ះពាល់ដោយគ្មានហេតុផលសមរម្យដល់អាជីវកម្មធម្មតានៃគំនូរឧស្សាហកម្មដែលបានការពារ និងមិនធ្វើឱ្យខូចខាតដោយគ្មានហេតុផលសមរម្យដល់ប្រយោជន៍ស្របច្បាប់នៃម្ចាស់គំនូរឧស្សាហកម្មដែលបានការពារ ដោយពិចារណាដល់ផលប្រយោជន៍ស្របច្បាប់នៃតតិយជន។

៣- រយៈពេលនៃកិច្ចការពារ ត្រូវកំណត់យ៉ាងហោចណាស់១០(ដប់)ឆ្នាំ។

# ផ្នែកទី៥ : ប្រកាសនីយបត្រតក្កកម្ម

## មាត្រា២៧

## កម្មវត្ថុដែលអាចទទួលបានប្រកាសនីយបត្រតក្កកម្ម

១- លើកលែងបទប្បញ្ញត្តិនៃកថាខណ្ឌទី២និងទី៣ ប្រកាសនីយបត្រតក្កកម្ម អាចទទួលបាន ចំពោះតក្កកម្មណាមួយ ទោះជាជាផលិតផលឬដំណើរការផលិត ក្នុងគ្រប់វិស័យបច្ចេកវិទ្យា ឱ្យតែតក្កកម្មនោះ ថ្មី មានជំហានរកឃើញថ្មីនិងអាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម[៥]។ លើកលែងកថាខណ្ឌទី៤នៃមាត្រា៦៥ កថាខណ្ឌទី៨នៃមាត្រា៧០ និងកថាខណ្ឌទី៣ នៃមាត្រានេះ ប្រកាសនីយបត្រតក្កកម្មអាចទទួលបាន ហើយសិទ្ធិប្រកាសនីយបត្រតក្កកម្មអាចផ្តល់ឱ្យ

---

[៥] [កំណត់សម្គាល់របស់កិច្ចព្រមព្រៀងTRIPS]ជាគោលបំណងនៃមាត្រានេះ ពាក្យថា "មានជំហានរកឃើញថ្មី-Inventive step" និងពាក្យថា "អាចយកទៅអនុវត្តបានក្នុងវិស័យឧស្សាហកម្ម- Capable of industrial application" អាចយល់ដោយ សមាជិកថាមានន័យដូចគ្នាទៅនឹង ពាក្យ "មិនសាមញ្ញ-Non-obvious" និងពាក្យ "មានប្រយោជន៍- Useful" តាមករណីនីមួយៗ ។

ដោយគ្មានរើសអើងចំពោះទីកន្លែងនៃតក្កកម្ម ចំពោះវិស័យបច្ចេកវិទ្យា ហើយទោះបីបើជាផលិតផលដែលនាំចូល ឬផលិតក្នុងស្រុកក៏ដោយ។

២- សមាជិកទាំងឡាយអាចដកចេញតក្កកម្មដែលអាចទទួលបានប្រកាសនីយបត្រតក្កកម្ម ទប់ស្កាត់ការធ្វើអាជីវកម្មបែបពាណិជ្ជកម្មក្នុងដែនដីរបស់ខ្លួន ដែលចាំបាច់ដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈឬសីលធម៌ រួមមាន ការពារជីវិតនិងសុខភាពរបស់ មនុស្ស សត្វ ឬ រុក្ខជាតិ ឬដើម្បីជៀសវាងធ្វើឱ្យខូចបរិស្ថានធ្ងន់ធ្ងរ ឱ្យតែការដកចេញនេះមិនធ្វើឡើងដោយសារតែការធ្វើអាជីវកម្មនេះ ត្រូវហាមឃាត់ដោយច្បាប់នោះឡើយ។

៣- សមាជិកទាំងឡាយអាចដកចេញពីភាពដែលអាចទទួលបានប្រកាសនីយបត្រតក្កកម្មផងដែរនូវ :

ក- វិធីសាស្ត្រវិនិច្ឆ័យរោគ វិធីសាស្ត្រព្យាបាល និងវិធីសាស្ត្រវះកាត់សម្រាប់ព្យាបាល មនុស្សឬសត្វ ។

ខ- រុក្ខជាតិនិងសត្វដែលមិនមែនជាមីក្រូសរីរាង្គនិងដំណើរការកកើតតាមលក្ខណៈជីវសាស្ត្រសំខាន់ៗសម្រាប់ផលិតកម្មរុក្ខជាតិឬសត្វ មិនមែនជាដំណើរការតាមលក្ខណៈមិនមែនជីវសាស្ត្រនិងមីក្រូជីវសាស្ត្រ។ ប៉ុន្តែសមាជិកទាំងឡាយត្រូវចែងពីកិច្ចការពារប្រភេទផ្សេងៗនៃពូជរុក្ខជាតិ ដោយប្រកាសនីយបត្រតក្កកម្មឬដោយប្រព័ន្ធដោយឡែកដែលមានប្រសិទ្ធភាព ឬដោយបន្សំនៃប្រព័ន្ធទាំងពីរ។បទប្បញ្ញត្តិនៃអនុកថាខណ្ឌនេះត្រូវពិនិត្យឡើងវិញក្នុងរយៈពេល៤(បួន)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។

## មាត្រា២៨

## សិទ្ធិដែលបានប្រគល់ឱ្យ

១- ប្រកាសនីយបត្រតក្កកម្មមួយបានប្រគល់ឱ្យម្ចាស់នូវសិទ្ធិផ្តាច់មុខដូចខាងក្រោមៈ

ក- នៅពេលកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មជាផលិតផល ទប់ស្កាត់តតិយជនដោយគ្មានការយល់ព្រមពីម្ចាស់ ពីសកម្មភាពនៃ ការផលិត ការប្រើប្រាស់ ការផ្តត់ផ្តង់សម្រាប់លក់ ការលក់ ឬការនាំចូលផលិតផលនេះ[៦]ក្នុងគោលបំណងដូចខាងលើ។

ខ-នៅពេលកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មជាដំណើរការផលិតកម្ម ទប់ស្កាត់តតិយជន ដោយគ្មានការយល់ព្រមពីម្ចាស់ ពីសកម្មភាពនៃការប្រើប្រាស់ដំណើរការផលិតកម្ម

[៦] [កំណត់សម្គាល់របស់កិច្ចព្រមព្រៀងTRIPS] សិទ្ធិនេះក៏ដូចជាសិទ្ធិផ្សេងទៀតដែលបានផ្តល់ឱ្យតាមកិច្ចព្រមព្រៀងនេះចំពោះ ការប្រើប្រាស់ ការលក់ ការនាំចូលឬចែកចាយទំនិញ ជាកម្មវត្ថុនៃបទប្បញ្ញត្តិនៃមាត្រា៦។

និងពីសកម្មភាពនៃ ការប្រើប្រាស់ ការផ្ដត់ផ្គង់សម្រាប់លក់ ការលក់ ឬ ការនាំចូលក្នុងគោលបំណងដូចខាងលើយ៉ាងហោចណាស់នូវផលិតផល ដែលទទួលបានដោយផ្ទាល់ពីដំណើរការផលិតកម្មនេះ ។

២- ម្ចាស់ប្រកាសនីយបត្រតក្កកម្មក៏មានសិទ្ធិប្រគល់ឬផ្ទេរដោយសន្តតិកម្ម ប្រកាសនីយ-ប្រកាសនីយបត្រតក្កកម្ម និងមានសិទ្ធិចុះកិច្ចសន្យាអាជ្ញាប័ណ្ណបាន។

## មាត្រា២៩

## លក្ខខណ្ឌចំពោះអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្ម

១- សមាជិកទាំងឡាយត្រូវតម្រូវឱ្យអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មបង្ហាញអំពីតក្កកម្មក្នុងលក្ខណៈច្បាស់លាស់និងពេញលេញដើម្បីឱ្យបុគ្គលដែលមានកម្រិតជំនាញធម្មតាក្នុងជំនាញអាចអនុវត្តបាននូវតក្កកម្មនោះ និងអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំចង្អុលបង្ហាញវិធីដែលល្អជាងគេដើម្បីអនុវត្តតក្កកម្ម ដែលបានដឹងដោយតក្ករនៅពេលចុះកាលបរិច្ឆេទសុំចុះ បញ្ជីឬនៅពេលចុះកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ ក្នុងករណីអាទិភាពត្រូវបានអះអាង។

២- សមាជិកទាំងឡាយអាចតម្រូវឱ្យអ្នកដាក់ពាក្យសុំប្រកាសនីយបត្រតក្កកម្មផ្ដល់ព័ត៌មានដែលទាក់ទងនឹងការដាក់និងការផ្ដល់សំណុំលិខិតស្នើសុំបរទេស។

## មាត្រា៣០

## ការលើកលែងចំពោះសិទ្ធិដែលបានប្រគល់ឱ្យ

សមាជិកទាំងឡាយអាចផ្ដល់ការលើកលែងដែលមានកម្រិតចំពោះសិទ្ធិផ្ដាច់មុខដែលប្រគល់ឱ្យដោយប្រកាសនីយបត្រតក្កកម្ម ឱ្យតែការលើកលែងនេះមិនធ្វើឱ្យប៉ះពាល់ដោយគ្មានហេតុផលសមរម្យដល់អាជីវកម្មធម្មតានៃប្រកាសនីយបត្រតក្កកម្ម និងមិនធ្វើឱ្យខូចខាតដោយគ្មានហេតុផលសមរម្យដល់ប្រយោជន៍ស្របច្បាប់នៃម្ចាស់ប្រកាសនីយបត្រតក្កកម្ម ដោយពិចារណាដល់ផលប្រយោជន៍ស្របច្បាប់នៃតតិយជន។

## មាត្រា៣១

## ការប្រើប្រាស់ផ្សេងទៀតដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ

ក្នុងករណីដែលច្បាប់នៃប្រទេសជាសមាជិក អនុញ្ញាតចំពោះការប្រើប្រាស់[៧]ផ្សេងទៀតនូវកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មមួយ ដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ ដោយរួមបញ្ចូលទាំង

---

[៧] [ កំណត់សម្គាល់របស់កិច្ចព្រមព្រៀងTRIPS] "ការប្រើប្រាស់ផ្សេងៗ" សំដៅលើការប្រើប្រាស់ក្រៅពីអ្វីដែលអនុញ្ញាតឱ្យក្រោមមាត្រា ៣០។

ការប្រើប្រាស់ដោយរដ្ឋាភិបាល ឬតតិយជនដែលបានទទួលការអនុញ្ញាតពីរដ្ឋាភិបាល បទប្បញ្ញត្តិទាំងឡាយដូចខាងក្រោមត្រូវគោរព :

ក- ការអនុញ្ញាតចំពោះការប្រើប្រាស់នេះត្រូវពិចារណាលើគុណសម្បត្តិនៃការប្រើប្រាស់នីមួយៗ។

ខ- ការប្រើប្រាស់នេះអាចអនុញ្ញាតតែក្នុងករណី មុនការប្រើប្រាស់នេះ អ្នកស្នើសុំប្រើប្រាស់ បានព្យាយាមសុំការអនុញ្ញាតពីម្ចាស់សិទ្ធិលើបែបបទនិងលក្ខខណ្ឌពាណិជ្ជកម្មសមរម្យ ហើយការព្យាយាមនេះមិនបានសម្រេចក្នុងពេលវេលាសមស្រប។ សមាជិកអាចបដិសេធលក្ខខណ្ឌតម្រូវនេះ ក្នុងករណី ប្រទេសជាតិមានភាពអាសន្ន ឬកាលៈទេសៈដទៃទៀតដែលកើតឡើងជាបន្ទាន់បំផុតៗ ឬ ក្នុងករណីនៃការប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈពាណិជ្ជកម្ម។ ក្នុងស្ថានភាពប្រជាជាតិមានភាពអាសន្ន ឬកាលៈទេសៈដទៃទៀតដែលកើតឡើងជាបន្ទាន់បំផុត ម្ចាស់សិទ្ធិត្រូវបានជូនដំណឹងយ៉ាងឆាប់រហ័សដែលអាចធ្វើទៅបាន។ ក្នុងករណីនៃការប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈពាណិជ្ជកម្ម ដែលរដ្ឋាភិបាលឬអ្នកចុះកិច្ចសន្យា ដោយគ្មានស្រាវជ្រាវប្រកាសនីយបត្រតក្កកម្ម បានដឹងឬមានមូលដ្ឋានបង្ហាញថាបានដឹង ថាប្រកាសនីយបត្រតក្កកម្មដែលមានសុពលភាព កំពុងប្រើប្រាស់ឬនឹងប្រើប្រាស់ ដោយឬសម្រាប់រដ្ឋាភិបាល ម្ចាស់សិទ្ធិត្រូវបានជូនដំណឹងភ្លាម។

គ- វិសាលភាពនិងរយៈពេលនៃការប្រើប្រាស់នេះត្រូវកម្រិតចំពោះវត្ថុបំណងដែលបានអនុញ្ញាត។ ក្នុងករណីនៃវិស័យបច្ចេកវិជ្ជាសឺមីខុនដាក់ទ័រ ត្រូវអនុញ្ញាតតែចំពោះការប្រើប្រាស់ជាសាធារណៈមិនមានលក្ខណៈពាណិជ្ជកម្ម ឬចំពោះការប្រើប្រាស់ដើម្បីដោះស្រាយការអនុវត្តន៍ដែលត្រូវបានកំណត់ថាប្រឆាំងនឹងការប្រកួតប្រជែង បន្ទាប់ពីនីតិវិធីតុលាការឬរដ្ឋបាល។

ឃ- ការប្រើប្រាស់នេះត្រូវមានលក្ខណៈមិនផ្តាច់មុខ។

ង- ការប្រើប្រាស់នេះមិនអាចផ្ទេរបាន លើកលែងតែការផ្ទេរនេះធ្វើឡើង ជាមួយផ្នែកនៃសហគ្រាសឬមូលនិធិពាណិជ្ជកម្មដែលទទួលបាននូវការប្រើប្រាស់នេះ។

ច- ការប្រើប្រាស់នេះត្រូវបានអនុញ្ញាតសម្រាប់ ផ្គត់ផ្គង់ឱ្យបានបរិបូរណ៍ដល់ទីផ្សារក្នុងស្រុករបស់សមាជិកដែលអនុញ្ញាតការប្រើប្រាស់នេះ។

ឆ- លើកលែងចំពោះកិច្ចការពារផលប្រយោជន៍ស្របច្បាប់របស់បុគ្គលដែលទទួលការអនុញ្ញាត ការអនុញ្ញាតចំពោះការប្រើប្រាស់នេះអាចត្រូវបានបញ្ចប់ប្រសិនបើនិងនៅពេលដែលសភាពការណ៍ដែលនាំទៅរកការអនុញ្ញាតិនេះឈប់កើតឡើងនិងមិនអាចកើតឡើងម្តងទៀត។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវមានសមត្ថកិច្ចពិនិត្យឡើងវិញនូវអត្ថិភាពបន្តនៃសភាពការណ៍នេះតាមសំណើ ។

ជ- ម្ចាស់សិទ្ធិត្រូវទទួលបានប្រាក់សំណងសមស្របតាមស្ថានភាពនីមួយៗ ដោយគិតដល់តម្លៃសេដ្ឋកិច្ចនៃការអនុញ្ញាតនេះ ។

ឈ- សុពលភាពស្របច្បាប់នៃសេចក្តីសម្រេចណាមួយដែលទាក់ទងនឹងការអនុញ្ញាតឱ្យប្រើប្រាស់ ជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញតាមផ្លូវតុលាការឬការត្រួតពិនិត្យឡើងវិញជាឯករាជ្យ ដោយអាជ្ញាធរថ្នាក់ខ្ពស់ផ្សេងទៀត ក្នុងប្រទេសជាសមាជិកនោះ។

ញ-សេចក្តីសម្រេចណាមួយទាក់ទងនឹងប្រាក់សំណង ដែលត្រូវបង់សម្រាប់ការប្រើប្រាស់នេះ ជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញតាមផ្លូវតុលាការ ឬការត្រួតពិនិត្យឡើងវិញជាឯករាជ្យ ដោយអាជ្ញាធរថ្នាក់ខ្ពស់ផ្សេងទៀត ក្នុងប្រទេសជាសមាជិកនោះ។

ដ- សមាជិកទាំងឡាយមិនតម្រូវឱ្យអនុវត្តលក្ខខណ្ឌកំណត់ក្នុងអនុកថាខណ្ឌ(ខ) និង(ច) នៅពេលដែលការប្រើប្រាស់នេះត្រូវបានអនុញ្ញាតដើម្បីដោះស្រាយការអនុវត្តន៍ដែលត្រូវបានកំណត់ថាប្រឆាំងនឹងការប្រកួតប្រជែង បន្ទាប់ពីនីតិវិធីតុលាការឬរដ្ឋបាល ។ ភាពចាំបាច់ដើម្បីកែតម្រូវការអនុវត្តន៍ដែលប្រឆាំងនឹងការប្រកួតប្រជែង អាចត្រូវបានពិចារណាដើម្បីកំណត់បរិមាណប្រាក់សំណងក្នុងករណីទាំងនេះ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវមានអំណាចបដិសេធការបញ្ចប់ការអនុញ្ញាត ប្រសិនបើនិងនៅពេលដែលលក្ខខណ្ឌដែលនាំឱ្យមានការអនុញ្ញាតអាចកើតឡើងម្តងទៀត។

ឋ- នៅពេលដែល ការប្រើប្រាស់ត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មលើប្រកាសនីយបត្រតក្កកម្មមួយ ("ប្រកាសនីយបត្រតក្កកម្មទី២") ដែលមិនអាចធ្វើអាជីវកម្ម ដោយគ្មានរំលោភបំពានទៅលើប្រកាសនីយបត្រកម្មមួយទៀត ("ប្រកាសនីយបត្រតក្កកម្មទី១ ") លក្ខខណ្ឌបន្ថែមដូចខាងក្រោម ត្រូវអនុវត្តៈ

(i) តក្កកម្មដែលបានអះអាងក្នុងប្រកាសនីយបត្រតក្កកម្មទី២ ត្រូវពាក់ព័ន្ធការប្រើប្រាស់បច្ចេកទេសជឿនលឿនដែលចាត់ទុកថា មានសារៈសំខាន់ចំពោះសេដ្ឋកិច្ចដោយធៀបទៅនឹងតក្កកម្មដែលបានអះអាងក្នុងប្រកាសនីយបត្រតក្កកម្មទី១

(ii) ម្ចាស់ប្រកាសនីយបត្រតក្កកម្មទី១ មានសិទ្ធិលើអាជ្ញាប័ណ្ណឆ្លងក្នុងលក្ខខណ្ឌសមស្របដើម្បីប្រើប្រាស់តក្កកម្ម ដែលបានអះអាងក្នុងប្រកាសនីយបត្រតក្កកម្មទី២ និង

(iii) ការប្រើប្រាស់ដែលបានអនុញ្ញាតចំពោះប្រកាសនីយបត្រតក្កកម្មទី១ មិនអាចផ្ទេរបានឡើយ លើកលែងតែមានការផ្ទេរជាមួយប្រកាសនីយបត្រតក្កកម្មទី២។

## មាត្រា៣២

## ការលុបចោល/ការបាត់បង់សិទ្ធិ

ចំពោះការត្រួតពិនិត្យឡើងវិញតាមផ្លូវតុលាការនៃសេចក្តីសម្រេចណាមួយ ត្រូវបង្កើតឱ្យមានឱកាសដើម្បីលុបចោលឬធ្វើឱ្យបាត់បង់សិទ្ធិ ប្រកាសនីយបត្រតក្កកម្មណាមួយ។

## មាត្រា៣៣

## រយៈពេលនៃកិច្ចការពារ

រយៈពេលនៃកិច្ចការពារមិនត្រូវបញ្ចប់មុនផុតកំណត់រយៈពេល២០(ម្ភៃ) ឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យសុំ[៨]។

## មាត្រា៣៤

## ប្រកាសនីយបត្រតក្កកម្មដែលជាដំណើរការផលិតកម្ម : បន្ទុកភស្តុតាង

១- ជាគោលបំណងនៃនីតិវិធីរដ្ឋប្បវេណីដែលទាក់ទងនឹងការរំលោភបំពានសិទ្ធិរបស់ម្ចាស់ ដូចមានចែងក្នុងកថាខណ្ឌទី១(ខ)នៃមាត្រា២៨ ប្រសិនបើកម្មវត្ថុនៃប្រកាសនីយបត្រតក្កកម្មជាដំណើរការផលិតកម្មដើម្បីទទួលបានផលិតផល អាជ្ញាធរតុលាការមានអំណាចបញ្ជាឱ្យចុងចម្លើយបង្ហាញថាដំណើរការផលិតកម្មដើម្បីទទួលលបានផលិតផលដូចគ្នាមួយ ខុសពីដំណើរការផលិតកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្ម។ ដូច្នេះ សមាជិកទាំងឡាយអាចចែងក្នុងកាលៈទេសៈណាមួយដូចខាងក្រោម ថាផលិតផលដូចគ្នាណាមួយនៅពេលដែលផលិតដោយគ្មានការយល់ព្រមពីម្ចាស់ប្រកាសនីយបត្រតក្កកម្ម ត្រូវចាត់ទុកថាទទួលបានពីដំណើរការផលិតកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្ម លើកលែងតែមានភស្តុតាងផ្ទុយៈ

ក- ប្រសិនបើផលិតផលដែលទទួលបានពីដំណើរការផលិតកម្មដែលបានទទួលប្រកាសនីយបត្រតក្កកម្ម ជាផលិតផលថ្មី ។

ខ- ប្រសិនបើមានភាពដូចគ្នាច្រើនចំពោះផលិតផលដែលដូចគ្នា ត្រូវបានផលិតឡើងពីដំណើរការផលិតកម្មនោះ ហើយម្ចាស់ប្រកាសនីយបត្រតក្កកម្មមិនអាចបង្ហាញថាដំណើរ

[៨] [កំណត់សម្គាល់របស់កិច្ចព្រមព្រៀងTRIPS]ត្រូវយល់ថាសមាជិកទាំងឡាយដែលគ្មានប្រព័ន្ធផ្តល់ប្រកាសនីយបត្រតក្កកម្មដើម អាចកំណត់ឱ្យរយៈពេលនៃកិច្ចការពារ ត្រូវរាប់ចាប់ពីកាលបរិច្ឆេទនៃ ការដាក់ពាក្យសុំក្នុងប្រព័ន្ធ នៃការផ្តល់ប្រកាសនីយបត្រតក្កកម្ម។

ការផលិតកម្មនោះ ត្រូវបានគេប្រើប្រាស់យ៉ាងពិតប្រាកដ ទោះបីបើព្យាយាមបង្ហាញយ៉ាងណាក៏ដោយ។

២-សមាជិកណាមួយមានសិទ្ធិចែងថា បន្ទុកនៃភស្តុតាង ដែលបានបង្ហាញក្នុងកថាខណ្ឌទី១ជាបន្ទុករបស់អ្នករំលោភបំពានដែលត្រូវបានគេចោទប្រកាន់ តែក្នុងលក្ខខណ្ឌដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ត្រូវបានបំពេញ ឬតែក្នុងលក្ខខណ្ឌ ដូចមានចែងក្នុងអនុកថាខណ្ឌ(ខ) ត្រូវបានបំពេញ។

៣- នៅពេលបង្ហាញភ័ស្តុតាងផ្ទុយ ផលប្រយោជន៍ស្របច្បាប់របស់ចុងចម្លើយ ដើម្បីការពារការសម្ងាត់ផលិតកម្មនិងការសម្ងាត់ពាណិជ្ជកម្ម ត្រូវលើកយកមកពិចារណា។

## ផ្នែកទី៦: គំនូសបង្ហាញនៃសៀគ្វីបង្រួម

### មាត្រា៣៥

### ទំនាក់ទំនងជាមួយសន្ធិសញ្ញាស្តីពីកម្មសិទ្ធិបញ្ញាទាក់ទងនឹងសៀគ្វីបង្រួម

សមាជិកទាំងឡាយ យល់ព្រម ការពារគំនូសបង្ហាញនៃសៀគ្វីបង្រួម ( (ក្នុងកិច្ចព្រមព្រៀងនេះហៅថា"គំនូសបង្ហាញ") អនុលោមតាមមាត្រា២ដល់មាត្រា៧(លើកលែងកថាខណ្ឌទី៣ នៃមាត្រា៦) មាត្រា ១២ និងកថាខណ្ឌទី៣ នៃមាត្រា១៦នៃសន្ធិសញ្ញាស្តីពីកម្មសិទ្ធិបញ្ញាទាក់ទងនឹងសៀគ្វីបង្រួម ហើយជាងនេះទៅទៀត ត្រូវស្របតាមបទប្បញ្ញត្តិទាំងឡាយដូចខាងក្រោម។

### មាត្រា៣៦

### វិសាលភាពនៃកិច្ចការពារ

លើកលែងបទប្បញ្ញត្តិកថាខណ្ឌទី១នៃមាត្រា៣៧ សមាជិកទាំងឡាយត្រូវចាត់ទុកថាខុសច្បាប់ សកម្មភាពទាំងឡាយដូចខាងក្រោម ដែលធ្វើឡើងដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ[៩]: ការនាំចូល ការលក់ឬការចែកចាយក្នុងគោលបំណងពាណិជ្ជកម្មនូវគំនូសបង្ហាញដែលបានការពារ សៀគ្វីបង្រួមមានបញ្ចូលគំនូសបង្ហាញដែលបានការពារ ឬទំនិញដែលមានសៀគ្វីបង្រួម តែក្នុងករណីដែលទំនិញនេះនៅរក្សាគំនូសបង្ហាញដែលត្រូវបានផលិតឡើងវិញដោយខុសច្បាប់។

### មាត្រា៣៧

### សកម្មភាពដែលមិនតម្រូវឱ្យមានការអនុញ្ញាតពីម្ចាស់សិទ្ធិ

---

[៩] [កំណត់សម្គាល់របស់កិច្ចព្រមព្រៀងTRIPS]ពាក្យថា"ម្ចាស់សិទ្ធិ-Right holder" នៅក្នុងផ្នែកនេះ ត្រូវយល់ថាមានអត្ថន័យដូចគ្នានឹង ពាក្យ "ម្ចាស់សិទ្ធិ- Holder of the right " នៅក្នុងសន្ធិសញ្ញាស្តីពីកម្មសិទ្ធិបញ្ញាដែលទាក់ទងនឹងសៀគ្វីបង្រួម(IPIC) ។

១- ថ្វីបើមានចែងក្នុងមាត្រា៣៦ក៏ដោយ គ្មានសមាជិកណាមួយត្រូវចាត់ទុកថាខុសច្បាប់ការប្រព្រឹត្តសកម្មភាពណាមួយ ដូចមានចែងក្នុងមាត្រានេះទាក់ទងនឹងសៀគ្វីបង្រួមមានគំនូសបង្ហាញដែលត្រូវបានផលិតឡើងវិញដោយខុសច្បាប់ ឬទំនិញណាមួយដែលមានសៀគ្វីបង្រួម ដែលបុគ្គលប្រព្រឹត្តិឬបញ្ជាអោយប្រព្រឹត្តិអំពើទាំងនេះមិនបានដឹង ហើយគ្មានមូលដ្ឋានថាបានដឹង នៅពេលទទួលបានសៀគ្វីបង្រួមឬទំនិញដែលមានសៀគ្វីបង្រួម ថាសៀគ្វីបង្រួមដែលមានគំនូសបង្ហាញត្រូវបានផលិតឡើងវិញដោយខុសច្បាប់។ សមាជិកទាំងឡាយត្រូវចែងថា បន្ទាប់ពីបុគ្គលនោះបានទទួលការជូនដំណឹងសមរម្យថា គំនូសបង្ហាញនោះត្រូវបានផលិតឡើងវិញដោយខុសច្បាប់ បុគ្គលនោះអាចប្រព្រឹត្តិសកម្មភាពណាមួយទាក់ទងនឹងសន្និធិទំនិញក្នុងដៃ ឬបានបញ្ជាទិញមុនពេលនេះ ប៉ុន្តែត្រូវទទួលខុសត្រូវបង់ប្រាក់ ជូនម្ចាស់សិទ្ធិតាមចំនួនមួយដែលសមមូលទៅនឹងលាភការសមរម្យ ដែលត្រូវបង់តាមកិច្ចសន្យាអាជ្ញាប័ណ្ណដែលបានចរចាដោយសេរីទាក់ទងគំនូសបង្ហាញនេះ។

២- លក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ដល់(ដ)នៃមាត្រា៣១ត្រូវ អនុវត្តដូចគ្នាប៉ុន្តែអាចកែប្រែតាមការចាំបាច់ក្នុងករណីនៃការផ្តល់អាជ្ញាប័ណ្ណបញ្ជានៃគំនូសបង្ហាញឬការប្រើប្រាស់នៃគំនូសបង្ហាញ ដោយឬសម្រាប់រដ្ឋាភិបាល ដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ។

## មាត្រា៣៨

## រយៈពេលនៃកិច្ចការពារ

១- ក្នុងប្រទេសជាសមាជិកទាំងឡាយដែលតម្រូវការចុះបញ្ជីជាលក្ខខណ្ឌនៃកិច្ចការពាររយៈពេលនៃកិច្ចការពារគំនូសបង្ហាញ មិនត្រូវបញ្ចប់មុនផុតកំណត់រយៈពេល១០(ដប់)ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទនៃការដាក់សំណុំលិខិតស្នើសុំចុះបញ្ជីឬរាប់ចាប់ពីការធ្វើអាជីវកម្មផ្នែកពាណិជ្ជកម្មដំបូង ទោះជានៅទីណាក៏ដោយក្នុងពិភពលោក ។

២- ក្នុងប្រទេសជាសមាជិកទាំងឡាយដែលមិនតម្រូវឱ្យមានការចុះបញ្ជីជាលក្ខខណ្ឌនៃកិច្ចការពារ គំនូសបង្ហាញត្រូវការពារមិនតិចជាង១០(ដប់)ឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទនៃការធ្វើអាជីវកម្មផ្នែកពាណិជ្ជកម្មជាដំបូង ទោះជានៅទីណាក៏ដោយក្នុងពិភពលោក។

៣- ថ្វីបើមានចែងក្នុងកថាខណ្ឌទី១និង២ក៏ដោយ សមាជិក អាចចែងថា កិច្ចការពារ ត្រូវផុតកំណត់១៥(ដប់ប្រាំ)ឆ្នាំបន្ទាប់ពីការបង្កើតគំនូសបង្ហាញ។

## ផ្នែកទី៧ : កិច្ចការពារព័ត៌មានសម្ងាត់

### មាត្រា៣៩

១- ដើម្បីធានាឱ្យមានកិច្ចការពារប្រកបដោយប្រសិទ្ធភាព ប្រឆាំងនឹងការប្រកួតប្រជែងមិនស្មោះត្រង់ ដូចមានចែងក្នុងមាត្រា១០ស្ទួននៃអនុសញ្ញាទីក្រុងប៉ារីស(១៩៦៧) សមាជិកទាំងឡាយត្រូវការពារព័ត៌មានសម្ងាត់តាមកថាខណ្ឌទី២និងការពារទិន្នន័យដែលបានដាក់ជូនរដ្ឋាភិបាល ឬភ្នាក់ងាររដ្ឋាភិបាល តាមកថាខណ្ឌទី៣ ។

២- រូបវន្តបុគ្គលនិងនីតិបុគ្គលត្រូវមានលទ្ធភាពទប់ស្កាត់ព័ត៌មាន ដែលស្ថិតក្រោមការគ្រប់គ្រងស្របច្បាប់របស់ខ្លួន ពី ការបង្ហាញ ការទទួលបាន ឬការប្រើប្រាស់ដោយបុគ្គលផ្សេងទៀត ដោយគ្មានការយល់ព្រម ដែលផ្ទុយពីការអនុវត្ត[១០]ទៀងត្រង់ក្នុងវិស័យពាណិជ្ជកម្ម ឱ្យតែព័ត៌មានទាំងនេះ :

ក- សម្ងាត់ក្នុងន័យថាព័ត៌មាននេះ ទោះជាទាំងមូលឬក្នុងទិដ្ឋភាពជាក់លាក់និងបណ្តុំនៃធាតុក៏ដោយ មិនត្រូវបានដឹងឬមិនអាចទទួលបានយ៉ាងងាយដោយបុគ្គលក្នុងមជ្ឈដ្ឋានដែលមានទំនាក់ទំនងជាធម្មតាជាមួយប្រភេទព័ត៌មាននេះ

ខ- មានតម្លៃពាណិជ្ជកម្មដោយសារតែព័ត៌មាននេះសម្ងាត់ និង

គ- ជាកម្មវត្ថុនៃវិធានការសមស្របតាមកាលៈទេសៈ របស់បុគ្គលដែលមានសិទ្ធិគ្រប់គ្រងស្របច្បាប់លើព័ត៌មាននេះ ដើម្បីរក្សាជាការសម្ងាត់។

៣- ជាលក្ខខណ្ឌក្នុងការអនុម័តលើការចែកចាយផលិតផលឱសថ ឬផលិតផលគីមីកសិកម្មដែលប្រើប្រាស់សារធាតុគីមីថ្មី នៅពេលតម្រូវឱ្យមានការដាក់ការធ្វើតេស្តសម្ងាត់ឬទិន្នន័យផ្សេងទៀត ដែលការបង្កើតទាមទារនូវកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំង សមាជិកទាំងឡាយ ត្រូវការពារទិន្នន័យនេះប្រឆាំងនឹងការប្រើប្រាស់មិនស្មោះត្រង់ក្នុងវិស័យពាណិជ្ជកម្ម។ ជាងនេះទៅទៀត សមាជិកទាំងឡាយត្រូវការពារទិន្នន័យនេះប្រឆាំងនឹងការបើកបង្ហាញ លើកលែងតែចាំបាច់ដើម្បីការពារសាធារណៈជន ឬលើកលែងតែមានការចាត់វិធាការដើម្បីធានាថា ទិន្នន័យនោះ ត្រូវបានការពារ ប្រឆាំងនឹងការប្រើប្រាស់មិនស្មោះត្រង់ក្នុងវិស័យពាណិជ្ជកម្ម។

---

[១០] [កំណត់សម្គាល់របស់កិច្ចព្រមព្រៀងTRIPS] ជាគោលបំណងនៃបទប្បញ្ញត្តិនេះ ពាក្យថា "ផ្ទុយនឹងការអនុវត្តន៍ទៀងត្រង់ក្នុងវិស័យពាណិជ្ជកម្ម"យ៉ាងហោចណាស់មានន័យជាការអនុវត្តន៍នានា ដូចជា ការរំលោភកិច្ចសន្យា ការរំលោភទៅលើទំនុកចិត្ត និងការជម្រុញឱ្យមានការរំលោភបំពាន ហើយរួមបញ្ចូលនូវការទទួលបានព័ត៌មានសម្ងាត់ដោយតតិយជនដែលបានដឹងឬមានការធ្វេសប្រហែសយ៉ាងធ្ងន់ធ្ងរដែលមិនអាចដឹងបាន ថាការអនុវត្តន៍បែបនេះពាក់ព័ន្ធនឹងការទទួលបានព័ត៌មាន។

# ផ្នែកទី៨ :ការត្រួតពិនិត្យការអនុវត្តន៍ដែលប្រឆាំងនឹងការប្រកួតប្រជែងក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណ

## មាត្រា៤០

១- សមាជិកទាំងឡាយយល់ព្រមថា ការអនុវត្តន៍ ឬលក្ខខណ្ឌមួយចំនួនដែលទាក់ទងនឹងអាជ្ញាប័ណ្ណចំពោះកម្មសិទ្ធិបញ្ញាដែលរារាំងដល់ការប្រកួតប្រជែង អាចផ្តល់ផលអវិជ្ជមានចំពោះពាណិជ្ជកម្មហើយអាចរារាំងដល់ការផ្ទេរនិងការផ្សព្វផ្សាយបច្ចេកវិទ្យា។

២- គ្មានបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះរារាំង សមាជិកទាំងឡាយ មិនឱ្យចែងក្នុងច្បាប់របស់ខ្លួននូវការអនុវត្តន៍ ឬលក្ខខណ្ឌដែលទាក់ទងនឹងអាជ្ញាប័ណ្ណ ដែលអាចក្នុងករណីពិសេសខ្លះបង្កើតជាការរំលោភលើកម្មសិទ្ធិបញ្ញា ដោយមានផលអវិជ្ជមាន លើការប្រកួតប្រជែងក្នុងទីផ្សារដែលពាក់ព័ន្ធ។ ដូចដែលបានចែងខាងលើ ដោយអនុលោម តាមបទប្បញ្ញត្តិផ្សេងទៀតនៃកិច្ចព្រមព្រៀងនេះ សមាជិកណាមួយអាចអនុម័តនូវវិធានការសមស្របនានាដើម្បីទប់ស្កាត់ឬត្រួតពិនិត្យការអនុវត្តន៍ទាំងនេះ ដែលអាចមានដូចជា លក្ខខណ្ឌផ្តល់មកវិញផ្តាច់មុខ លក្ខខណ្ឌដែលរារាំងការតវ៉ាលើសុពលភាពនិងបង្ខំឱ្យទទួលយកអាជ្ញាប័ណ្ណកញ្ចប់ ដោយអនុតាមច្បាប់និងបទបញ្ញាដែលពាក់ព័ន្ធរបស់សមាជិកនោះ។

៣- តាមសំណើ សមាជិកនីមួយៗត្រូវចូលរួមក្នុងកិច្ចពិគ្រោះយោបល់ជាមួយសមាជិកណាមួយផ្សេងទៀត ដែលមានមូលហេតុគួរឱ្យជឿថា ម្ចាស់កម្មសិទ្ធិបញ្ញាដែលជាពលរដ្ឋឬនិវេសនជននៃសមាជិកដែលគេស្នើសុំពិគ្រោះយោបល់ កំពុងអនុវត្តដោយបំពានលើច្បាប់និងបទបញ្ញារបស់សមាជិកដែលស្នើសុំដែលទាក់ទងនឹងកម្មវត្ថុនៃផ្នែកនេះ ហើយមានបំណងធានាថាគោរពតាមច្បាប់នេះ ដោយមិនប៉ះពាល់ដល់វិធានការដែលមានចែងក្នុងច្បាប់ និងមិនប៉ះពាល់ដល់សេរីភាពទាំងស្រុងក្នុងការសម្រេចជាចុងក្រោយរបស់សមាជិកណាមួយ។ សមាជិកដែលគេបានស្នើសុំ ត្រូវធ្វើការពិចារណាទាំងស្រុងនិងប្រកបដោយសមានចិត្ត ហើយត្រូវផ្តល់ឱកាសសមរម្យ ចំពោះការពិគ្រោះយោបល់ជាមួយសមាជិកដែលស្នើសុំ ហើយត្រូវសហប្រតិបត្តិការដោយផ្តល់នូវព័ត៌មានមិនសម្ងាត់ដែលទាក់ទងនឹងបញ្ហាដែលលើកឡើងដល់សាធារណៈជន និងផ្តល់ព័ត៌មានផ្សេងទៀតដល់សមាជិកដែលស្នើសុំ លើកលែងតែមានច្បាប់ក្នុងស្រុកនិងមានការចុះកិច្ចព្រមព្រៀងទ្វេភាគីដែលទាក់ទងនឹងការគោរពការសម្ងាត់ដោយសមាជិកដែលស្នើសុំ។

៤- សមាជិកមួយ ដែលពលរដ្ឋឬនិវេសនជនរបស់ខ្លួន ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមនីតិវិធីរបស់សមាជិកមួយផ្សេងទៀត ចំពោះការចោទប្រកាន់ថាបំពានលើច្បាប់និងបទបញ្ញារបស់

សមាជិកនោះ ដែលជាកម្មវត្ថុនៃផ្នែកនេះ តាមសំណើ សមាជិកមួយនេះត្រូវបានផ្តល់ឱកាសឱ្យមានការពិគ្រោះយោបល់ដោយសមាជិកផ្សេងទៀត ក្នុងលក្ខខណ្ឌដូចគ្នាដូចមានចែងក្នុងកថាខណ្ឌទី៣ខាងលើ។

# ជំពូកទី៣
# ការអនុវត្តន៍សិទ្ធិកម្មសិទ្ធិបញ្ញា
## ផ្នែកទី១
## កាតព្វកិច្ចទូទៅ
### មាត្រា៤១

១- សមាជិកទាំងឡាយត្រូវធានាថា នីតិវិធីអនុវត្តដូចកំណត់ក្នុងជំពូកនេះ មានក្នុងច្បាប់របស់ខ្លួន ដើម្បីអនុញ្ញាតឱ្យមានវិធានការមានប្រសិទ្ធភាពប្រឆាំងនឹងសកម្មភាពនៃការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញាក្នុងកិច្ចព្រមព្រៀងនេះ ដែលរួមមាន ដំណោះស្រាយបន្ទាន់ ដើម្បីទប់ស្កាត់ការរំលោភបំពាននិងដំណោះស្រាយផ្សេងៗទៀត ដែលធ្វើឱ្យរាងចាលចំពោះការរំលោភបំពានផ្សេងទៀត។ នីតិវិធីទាំងនេះ ត្រូវអនុវត្តក្នុងលក្ខណៈមួយដើម្បីជៀសវាងការបង្កើតឧបសគ្គចំពោះការធ្វើអាជីវកម្មស្របច្បាប់និងផ្តល់កិច្ចការពារប្រឆាំងនឹងការរំលោភបំពាន។

២- នីតិវិធីដែលពាក់ព័ន្ធនឹងការអនុវត្តន៍សិទ្ធិកម្មសិទ្ធិបញ្ញាត្រូវមានភាពយុត្តិធម៌និងសមធម៌។ នីតិវិធីទាំងនេះមិនត្រូវមានភាពស្មុគ្រស្មាញដែលមិនចាំបាច់ឬមានតម្លៃខ្ពស់ ឬបង្កើតឱ្យមានការកំណត់រយៈពេលកម្រិតមិនសមរម្យ ឬពន្យាពេលដោយគ្មានហេតុផល។

៣- សេចក្តីសម្រេចដល់អង្គសេចក្តីនៃរឿងក្តីមួយ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរនិងមានសំអាង។ យ៉ាងហោចណាស់ភាគីនៃនីតីវិធីត្រូវទទួលបានសេចក្តីសម្រេចទាំងនេះ ដោយគ្មានការពន្យាពេលមិនសមហេតុផល។សេចក្តីសម្រេចដល់អង្គសេចក្តីនៃរឿងក្តី ត្រូវធ្វើឡើងដោយផ្អែកលើភស្តុតាងតែប៉ុណ្ណោះ ដោយភាគីទាំងឡាយត្រូវបានផ្តល់ឱកាសឱ្យមានសិទ្ធិតតាំងក្នុងសវនាការ។

៤- ភាគីនៃនីតីវិធីត្រូវមានឱកាសសម្រាប់ការត្រួតពិនិត្យឡើងវិញដោយអាជ្ញាធរតុលាការចំពោះសេចក្តីសម្រេចរដ្ឋបាលចុងក្រោយ លើកលែងតែបទប្បញ្ញត្តិយុត្តាធិការក្នុងច្បាប់នៃសមាជិកពាក់ព័ន្ធទៅនឹងសារៈសំខាន់នៃរឿងក្តី យ៉ាងហោចណាស់សារៈសំខាន់នៃទិដ្ឋភាពច្បាប់នៃសេចក្តីសម្រេចដល់អង្គសេចក្តីនៃរឿងក្តីរបស់តុលាការដំបូង។ ប៉ុន្តែគ្មានកាតព្វកិច្ច ផ្តល់ឱកាសដើម្បីត្រួតពិនិត្យឡើងវិញការសម្រេចដោះលែង ក្នុងរឿងព្រហ្មទណ្ឌ។

៥- ត្រូវយល់ថា ជំពូកនេះមិនបង្កើតកាតព្វកិច្ចណាមួយដើម្បីបង្កើតប្រព័ន្ធតុលាការមួយចំពោះការអនុវត្តន៍សិទ្ធិកម្មសិទ្ធិបញ្ញា ខុសពីប្រព័ន្ធនៃការអនុវត្តច្បាប់ទូទៅនោះឡើយឬមិនធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពនៃសមាជិកទាំងឡាយក្នុងការអនុវត្តន៍ច្បាប់ជាទូទៅរបស់ខ្លួន។ ក្នុងជំពូកនេះគ្មានបទប្បញ្ញត្តិ ដែលបង្កើតជាកាតព្វកិច្ចណាមួយចំពោះការបែងចែកធនធានរវាងការអនុវត្តន៍សិទ្ធិកម្មសិទ្ធិបញ្ញានិងការអនុវត្តន៍ច្បាប់ជាទូទៅទេ។

## ផ្នែកទី២ : នីតិវិធីរដ្ឋប្បវេណីនិងរដ្ឋបាល និងវិធានការដោះស្រាយ

### មាត្រា៤២

### នីតិវិធីយុត្តិធម៌និងសមធម៌

សមាជិកទាំងឡាយ ត្រូវបង្កើតឱ្យមាននីតិវិធីតុលាការផ្នែករដ្ឋប្បវេណី[១១]ដល់ម្ចាស់សិទ្ធិពាក់ព័ន្ធនឹងការអនុវត្តន៍សិទ្ធិកម្មសិទ្ធិបញ្ញាដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ។ ចុងចម្លើយត្រូវមានសិទ្ធិទទួលការជូនដំណឹងជាលាយលក្ខណ៍ឱ្យទាន់ពេលវេលានិងមានការលម្អិតគ្រប់គ្រាន់រួមទាំងមូលដ្ឋាននៃបណ្ដឹង។ ភាគីទាំងឡាយត្រូវបានអនុញ្ញាតឱ្យមានតំណាងជាមេធាវីឯករាជ្យ ហើយនីតិវិធីមិនតម្រូវឱ្យមានលក្ខខណ្ឌតឹងរឹងហួសហេតុពាក់ព័ន្ធនឹងការចូលខ្លួនជាកំហិត។ ភាគីទាំងអស់នៃនីតិវិធី ត្រូវមានសិទ្ធិលើកឡើងពីការអះអាងរបស់ខ្លួននិងបង្ហាញភស្តុតាងទាំងអស់ដែលពាក់ព័ន្ធ។ នីតិវិធីនេះត្រូវផ្តល់នូវមធ្យោបាយដើម្បីបង្ហាញនិងការពារព័ត៌មានសម្ងាត់ លើកលែងតែការនេះផ្ទុយនឹងលក្ខខណ្ឌតម្រូវនៃរដ្ឋធម្មនុញ្ញដែលមានស្រាប់។

### មាត្រា៤៣

### ភស្តុតាង

១- អាជ្ញាធរតុលាការមានអំណាច នៅពេលដែលភាគីមួយបានបង្ហាញភស្តុតាងសមស្រប ដែលគ្រប់គ្រាន់ដើម្បីគាំទ្រការអះអាងរបស់ខ្លួន និងបានបង្ហាញនូវភស្តុតាងជាក់លាក់ដើម្បីគាំទ្រការអះអាងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភាគីជំទាស់ ដើម្បីបញ្ជាឱ្យភាគីជំទាស់លើកឡើងនូវភស្តុតាង លើកលែងតែមានលក្ខខណ្ឌដែលធានាការពារ ព័ត៌មានសម្ងាត់ ។

២- ក្នុងករណីដែលភាគីមួយនៃនីតិវិធី បដិសេធដោយស្ម័គ្រចិត្ត និងដោយគ្មានហេតុផលត្រឹមត្រូវសិទ្ធិទទួលព័ត៌មានចាំបាច់ ឬមិនផ្តល់ព័ត៌មានចាំបាច់ក្នុងរយៈពេលសមរម្យ ឬរារាំងដល់

[១១] [កំណត់សម្គាល់របស់កិច្ចព្រមព្រៀងTRIPS ] ជាគោលបំណងនៃជំពូកនេះពាក្យថា "ម្ចាស់សិទ្ធិ" រួមមាន សហព័ន្ធនិងសមាគមដែលមានសមត្ថភាពផ្លូវច្បាប់ក្នុងការអះអាងសិទ្ធិនេះ។

នីតិវិធីចំពោះបណ្ដឹងឱ្យអនុវត្តសិទ្ធិ សមាជិក អាចផ្តល់សមត្ថកិច្ចឱ្យអាជ្ញាធរតុលាការសម្រេចជាបឋមនិងចុងក្រោយ ទោះវិជ្ជមានឬអវិជ្ជមានក្ដី ដោយយោងទៅលើមូលដ្ឋាននៃព័ត៌មានដែលបានបង្ហាញ រួមទាំងបណ្ដឹងឬការចោទប្រកាន់ ដោយភាគីខូចប្រយោជន៍ដោយការបដិសេធមិនផ្ដល់ព័ត៌មាន លើកលែងតែមានការផ្ដល់ឱកាសឱ្យភាគីទាំងឡាយតតាំងចំពោះការចោទប្រកាន់ ឬភស្តុតាង។

## មាត្រា៤៤

## ដីកាបញ្ជា

១- អាជ្ញាធរតុលាការ មានអំណាចបញ្ជាឱ្យភាគីណាមួយបញ្ឈប់ការរំលោភបំពាន ដូចជាដើម្បីទប់ស្កាត់ ការហូរចូលក្នុងបណ្ដាញពាណិជ្ជកម្មក្នុងយុត្តាធិការរបស់ខ្លួននូវទំនិញនាំចូលដែលពាក់ព័ន្ធនឹងការរំលោភសិទ្ធិកម្មសិទ្ធិបញ្ញា ភ្លាមបន្ទាប់ពីការត្រួតពិនិត្យទំនិញរបស់គយ។ សមាជិកទាំងឡាយមិនតម្រូវឱ្យផ្ដល់អំណាចនេះចំពោះកម្មវត្ថុដែលបានការពារដែលទទួលបាន ឬត្រូវបញ្ជាដោយបុគ្គលណាមួយ មុនពេលដឹងឬមានមូលដ្ឋានសមស្របថាដឹង ថាអាជីវកម្មលើកម្មវត្ថុនេះនឹងរំលោភសិទ្ធិកម្មសិទ្ធិបញ្ញា។

២- ថ្វីបើមានចែងក្នុបទប្បញ្ញត្តិផ្សេងទៀតនៃជំពូកនេះ និងឱ្យតែបទប្បញ្ញត្តិនៃជំពូកទី២ បានកំណត់ជាក់លាក់ អំពីការប្រើប្រាស់ដោយរដ្ឋាភិបាលឬដោយតតិយជនដែលបានអនុញ្ញាតពីរដ្ឋាភិបាល ដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិ សមាជិកទាំងឡាយអាចកម្រិតវិធានការដោះស្រាយដែលមាន ប្រឆាំងនឹងការប្រើប្រាស់នេះ ដោយបង់លាភការតាមអនុកថាខណ្ឌ(ជ)នៃមាត្រា៣១។ ក្នុងករណីផ្សេងទៀត វិធានការដោះស្រាយក្នុងជំពូកនេះ ត្រូវអនុវត្តឬនៅពេលដែលវិធានការដោះស្រាយទាំងនេះមិនស្របជាមួយច្បាប់នៃសមាជិក ត្រូវឱ្យមាន សាលក្រមប្រកាសទទួលស្គាល់និងសំណងសមរម្យ។

## មាត្រា៤៥

## ការខូចខាត

១- អាជ្ញាធរតុលាការ មានអំណាចបញ្ជាឱ្យជនល្មើសបង់ឱ្យម្ចាស់សិទ្ធិនូវសំណងសមរម្យចំពោះការខូចខាតដែលម្ចាស់សិទ្ធិបានទទួលរងគ្រោះ ពីការរំលោភសិទ្ធិកម្មសិទ្ធិបញ្ញារបស់ខ្លួនដោយជនល្មើសដែលបានដឹង ឬមានមូលដ្ឋានសមរម្យថាដឹង បានចូលរួមក្នុងសកម្មភាពរំលោភបំពាន។

២- អាជ្ញាធរតុលាការ មានអំណាចបញ្ជាផងដែរឱ្យជនល្មើសបង់លើការចំណាយនានា

របស់ម្ចាស់សិទ្ធិ ដែលអាចរួមទាំងសេវាមេធាវីសមរម្យផងដែរ។ ក្នុងករណីសមស្រប សមាជិកទាំងឡាយ អាចអនុញ្ញាតឱ្យអាជ្ញាធរតុលាការបញ្ជាឱ្យទារនូវប្រាក់ចំណេញ និង/ឬបង់ការខូចខាតដែលមានពីមុនៗ ទោះបីជនល្មើសមិនបានដឹងឬគ្មានមូលដ្ឋានសមរម្យថាដឹង បានចូលរួមក្នុងសកម្មភាពរំលោភបំពាន ។

## មាត្រា៤៦

## វិធានការដោះស្រាយផ្សេងទៀត

ដើម្បីបង្កើតឱ្យមានភាពរាងចាលដែលមានប្រសិទ្ធិភាពចំពោះការរំលោភបំពាន អាជ្ញាធរតុលាការមានអំណាចបញ្ជាឱ្យទំនិញដែលរកឃើញថារំលោភបំពាន ត្រូវដកចេញពីបណ្តាញពាណិជ្ជកម្ម ដោយគ្មានសំណង ដើម្បីបញ្ចៀសនូវព្យសនកម្មចំពោះម្ចាស់សិទ្ធិ ឬ ត្រូវបំផ្លាញចោល លើកលែងតែអំពើនេះផ្ទុយនឹងលក្ខខណ្ឌតម្រូវនៃរដ្ឋធម្មនុញ្ញដែលមានស្រាប់។អាជ្ញាធរតុលាការក៏មានអំណាចបញ្ជាឱ្យសំភារៈនិងឧបករណ៍ដែលប្រើប្រាស់ជាចំបង ដើម្បីផលិតទំនិញល្មើស ត្រូវដកចេញពីបណ្តាញពាណិជ្ជកម្ម ដោយគ្មានសំណង ដើម្បីកាត់បន្ថយជាអប្បបរមានូវហានិភ័យនៃការរំលោភបំពានផ្សេងទៀត។ ក្នុងការពិចារណាលើសំណើនេះ ត្រូវគិតគូរដល់សមាមាត្រនៃភាពធ្ងន់ធ្ងរនៃការរំលោភបំពាន វិធានការដោះស្រាយ ក៏ដូចជាផលប្រយោជន៍របស់តតិយជន។ ចំពោះទំនិញក្លែងបន្លំម៉ាក គ្រាន់តែដកម៉ាកដែលបំពាក់ខុសច្បាប់ចេញ មិនគ្រប់គ្រាន់ទេ ដើម្បីអនុញ្ញាតឱ្យដោះលែងទំនិញឱ្យចូលក្នុងបណ្តាញពាណិជ្ជកម្ម លើកលែងតែមានអញ្ញត្រកម្ម។

## មាត្រា៤៧

## សិទ្ធិទទួលបានព័ត៌មាន

សមាជិកទាំងឡាយអាចចែងថា អាជ្ញាធរតុលាការមានអំណាចបញ្ជាឱ្យជនល្មើស ជូនដំណឹងដល់ម្ចាស់សិទ្ធិពីអត្តសញ្ញាណរបស់តតិយជនដែលពាក់ព័ន្ធនឹង ការផលិតនិងចែកចាយទំនិញឬសេវាដែលល្មើស និងពីបណ្តាញចែកចាយ លើកលែងតែការធ្វើរបៀបនេះហួសពីសមាមាត្រនៃភាពធ្ងន់ធ្ងរនៃការរំលោភបំពាន ។

## មាត្រា៤៨

## សំណងចំពោះចុងចម្លើយ

១- អាជ្ញាធរតុលាការ មានអំណាចបញ្ជាឱ្យភាគីដែលបានស្នើឱ្យដាក់ចេញវិធានការ ហើយដែលបានរំលោភនីតិវិធីនៃការអនុវត្តន៍សិទ្ធិ ឱ្យផ្តល់ឱ្យភាគីដែលត្រូវបានបង្គាប់ឱ្យធ្វើឬឃាត់ឃាំង

មិនត្រឹមត្រូវនូវសំណងសមរម្យចំពោះការខូចខាតដោយសារការរំលោភបំពាននេះ។ អាជ្ញាធរតុលាការក៏មានអំណាច បញ្ជាឱ្យអ្នកប្តឹងបង់ចំពោះការចំណាយនានាដល់ចុងចម្លើយដែលអាចរួមទាំងសេវាមេធាវីសមរម្យផងដែរ។

២- ចំពោះការគ្រប់គ្រងច្បាប់ណាមួយដែលពាក់ព័ន្ធនឹងកិច្ចការពារ ឬការអនុវត្តន៍កម្មសិទ្ធិបញ្ញា សមាជិកទាំងឡាយត្រូវលើកលែងចំពោះតែអាជ្ញាធរនិងមន្ត្រីសាធារណៈ ពីការទទួលខុសត្រូវ លើវិធានការដោះស្រាយសមរម្យណាដែលត្រូវបានចាត់ ឬធ្វើឡើងដោយសុចរិតក្នុងដំណើការគ្រប់គ្រងច្បាប់នេះ។

## មាត្រា៤៩

## នីតិវិធីរដ្ឋបាល

ក្នុងករណីដែលមានការចាត់វិធានការដោះស្រាយផ្នែករដ្ឋប្បវេណី បន្ទាប់ពីមាននីតិវិធីរដ្ឋបាលទាក់ទងដល់អង្គសេចក្តី នីតិវិធីនេះត្រូវអនុលោមតាមគោលការណ៍សារធាតុដែលសមមូលនឹងគោលការណ៍ទាំងឡាយដូចមានចែងក្នុងផ្នែកនេះ។

# ផ្នែកទី៣: វិធានការបណ្តោះអាសន្ន

## មាត្រា៥០

១- អាជ្ញាធរតុលាការមានអំណាចចេញវិធានការបណ្តោះអាសន្នជាបន្ទាន់និង មានប្រសិទ្ធភាពដើម្បី:

ក- ទប់ស្កាត់ការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញាមិនឱ្យកើតមានឡើង ហើយដោយឡែកដើម្បីទប់ស្កាត់ការហូរចូលទំនិញក្នុងបណ្តាញពាណិជ្ជកម្ម ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមទាំងទំនិញនាំចូល ភ្លាមបន្ទាប់ពីការត្រួតពិនិត្យរបស់គយ។

ខ- រក្សាទុកភស្តុតាងដែលពាក់ព័ន្ធ ចំពោះការរំលោភបំពានដែលបានចោទប្រកាន់

២- អាជ្ញាធរតុលាការមានអំណាចអនុម័តវិធានការបណ្តោះអាសន្ន ដោយមិនស្តាប់ចម្លើយភាគីផ្សេងទៀត ក្នុងករណីចាំបាច់ ជាពិសេសនៅពេលការយឺតយ៉ាវ អាចបណ្តាលឱ្យអន្តរាយដែលមិនអាចជួសជុលបានចំពោះម្ចាស់សិទ្ធិ ឬនៅពេលដែលមានហានិភ័យដល់ការបំផ្លាញភស្តុតាង។

៣- អាជ្ញាធរតុលាការ មានអំណាចតម្រូវឱ្យអ្នកប្តឹងផ្តល់ភស្តុតាងត្រឹមត្រូវដែលមានដើម្បីធ្វើឱ្យតុលាការយល់ស្របក្នុងកម្រិតមួយច្បាស់លាស់គ្រប់គ្រាន់ ថាអ្នកប្តឹងគឺជាម្ចាស់សិទ្ធិហើយសិទ្ធិរបស់អ្នកប្តឹងកំពុងត្រូវបានគេរំលោភឬការរំលោភនោះអាចនឹងកើតមានឡើងក្នុងពេលឆាប់ៗ

និងបញ្ជាឱ្យអ្នកប្តឹងផ្តល់នូវប្រាក់ធានាឬការធានាដែលមានតម្លៃស្មើ គ្រប់គ្រាន់ដើម្បី ការពារចុងចម្លើយនិងដើម្បីទប់ស្កាត់មិនឱ្យមានការរំលោភបំពាន។

៤- នៅពេលដែលចេញវិធានការបណ្តោះអាសន្ន ដោយមិនស្តាប់ចម្លើយភាគីផ្សេងទៀត ភាគីដែលប៉ះពាល់ត្រូវបានជូនដំណឹងដោយមិនពន្យាពេល បន្ទាប់ពីចាត់វិធានការភ្លាម។ ការពិនិត្យឡើងវិញ រួមទាំងសិទ្ធិតតាំងក្នុងសវនាការត្រូវធ្វើឡើងតាមសំណើរបស់ចុងចម្លើយដើម្បីសម្រេច ថាវិធានការទាំងនេះ ត្រូវ កែតម្រូវ លុបចោល ឬតម្កល់ក្នុងរយៈពេលមួយសមស្រប បន្ទាប់ពីការជូនដំណឹងនៃវិធានការនេះ ។

៥- អ្នកប្តឹងអាចត្រូវបានតម្រូវឱ្យផ្តល់នូវព័ត៌មានចាំបាច់ផ្សេងទៀត ដើម្បីកំណត់អត្តសញ្ញាណទំនិញដែលពាក់ព័ន្ធ ដោយអាជ្ញាធរដែលនឹងចាត់វិធានការបណ្តោះអាសន្ននេះ។

៦- ដោយមិនធ្វើឱ្យប៉ះពាល់ដល់កថាខណ្ឌទី៤ តាមសំណើចុងចម្លើយ វិធានការបណ្តោះអាសន្នដែលត្រូវបានចេញតាមខណ្ឌទី១និងទី២ ត្រូវលុបចោល ឬលែងឱ្យមានអានុភាព ប្រសិនបើនីតិវិធីដែលនាំឱ្យមានសេចក្តីសម្រេចដល់អង្គសេចក្តីនៃរឿងក្តី មិនត្រូវបានផ្តួចផ្តើមក្នុងរយៈពេលមួយសមស្រប ដែលនឹងត្រូវកំណត់ដោយអាជ្ញាធរតុលាការដែលចេញវិធានការ នៅពេលដែលច្បាប់របស់សមាជិកអនុញ្ញាត ឬបើគ្មានកំណត់បែបនេះ ត្រូវធ្វើឡើងក្នុងរយៈពេល មិនលើសពី២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការឬ៣១(សាមសិបមួយ)ថ្ងៃនៃថ្ងៃប្រតិទិន ដោយយករយៈពេលណាដែលយូរជាងគេ។

៧- នៅពេលដែលវិធានការបណ្តោះអាសន្នត្រូវបានលុបចោល ឬអស់សុពលភាពដោយសារសកម្មភាពឬអកម្មភាពរបស់អ្នកប្តឹងឬនៅពេលបន្ទាប់មករកឃើញថា គ្មានការរំលោភបំពាន ឬការគំរាមរំលោភបំពានកម្មសិទ្ធិបញ្ញាទេ តាមសំណើរបស់ចុងចម្លើយ អាជ្ញាធរតុលាការមានអំណាចបញ្ជាឱ្យអ្នកប្តឹង ផ្តល់សំណងសមស្របដល់ចុងចម្លើយ ចំពោះការខូចខាតនានាដែលកើតមានឡើងដោយការអនុវត្តន៍វិធានការទាំងនេះ។

៨- ក្នុងករណីដែលវិធានការបណ្តោះអាសន្នណាមួយត្រូវបានចេញ តាមនីតិវិធីរដ្ឋបាល នីតិវិធីនេះត្រូវអនុលោមតាមគោលការណ៍សារធាតុ ដែលសមមូលនឹងគោលការណ៍ទាំងឡាយដូចមានចែងក្នុងផ្នែកនេះ។

## ផ្នែកទី៤ : លក្ខខណ្ឌតម្រូវជាពិសេសទាក់ទងនឹងវិធានការតាមមាត់ច្រកព្រំដែន[១២]

### មាត្រា៥១

### ការព្យួរទុកការដោះលែងទំនិញដោយអាជ្ញាធរគយ

អនុលោមតាមបទប្បញ្ញត្តិកំណត់ដូចខាងក្រោម សមាជិកទាំងឡាយត្រូវអនុម័តនីតិវិធី[១៣]ដែលអាចឱ្យម្ចាស់សិទ្ធិដែលមានមូលដ្ឋានស្របច្បាប់សង្ស័យថា អាចកើតមានឡើងការនាំចូលទំនិញពាក់ម៉ាកក្លែងក្លាយ ឬទំនិញថតចម្លងរំលោភសិទ្ធិអ្នកនិពន្ធ[១៤]ដើម្បីដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ចដែលជាអាជ្ញាធររដ្ឋបាលឬតុលាការ ឱ្យអាជ្ញាធរគយព្យួរការដោះលែងទំនិញមិនឱ្យចរាចរដោយសេរី។ សមាជិកទាំងឡាយអាចអនុញ្ញាតឱ្យមានការធ្វើបណ្ដឹងបែបនេះចំពោះទំនិញដែលពាក់ព័ន្ធនឹងការរំលោភកម្មសិទ្ធិបញ្ញាផ្សេងទៀត ឱ្យតែលក្ខខណ្ឌតម្រូវក្នុងផ្នែកនេះត្រូវបានបំពេញ។ សមាជិកទាំងឡាយអាចចែងពីនីតិវិធីពាក់ព័ន្ធដែលទាក់ទងនឹងការព្យួរទុកដោយអាជ្ញាធរគយ ការដោះលែងទំនិញល្មើសសម្រាប់នាំចេញពីដែនដីរបស់ខ្លួន។

### មាត្រា៥២

### បណ្ដឹង

ម្ចាស់សិទ្ធិណាមួយដែលផ្ដើមនីតិវិធីក្នុងមាត្រា៥១ តម្រូវឱ្យផ្ដល់ភស្តុតាងគ្រប់គ្រាន់ ដើម្បី

---

[១២] [កំណត់សម្គាល់របស់កិច្ចព្រមព្រៀងTRIPS] នៅពេលដែលសមាជិកមួយ បានដកផ្នែកសំខាន់ចេញពីការត្រួតពិនិត្យលើចលនានៃទំនិញ ឆ្លងកាត់ព្រំដែនជាមួយនឹងសមាជិកមួយផ្សេងទៀត ដែលបង្កើតជាផ្នែកនៃសហភាពគយ សមាជិកនេះមិនតម្រូវឱ្យអនុវត្តបទប្បញ្ញត្តិទាំងឡាយនៃផ្នែកនេះ នៅតាមព្រំដែនទេ។

[១៣] [កំណត់សម្គាល់របស់កិច្ចព្រមព្រៀងTRIPS] ត្រូវយល់ថាគ្មានកាតព្វកិច្ចអោយអនុវត្តនីតិវិធីនេះចំពោះការនាំចូលទំនិញដែលបានដាក់លក់លើទីផ្សារក្នុងប្រទេសមួយផ្សេងទៀតដោយម្ចាស់សិទ្ធិឬមានការយល់ព្រមពីម្ចាស់សិទ្ធិឬចំពោះទំនិញដែលឆ្លងកាត់។

[១៤] [កំណត់សម្គាល់របស់កិច្ចព្រមព្រៀងTRIPS ] ជាគោលបំណងនៃកិច្ចព្រមព្រៀងនេះ:

ក. "ទំនិញពាក់ម៉ាកក្លែងក្លាយ" មានន័យថា ទំនិញណាមួយ រួមទាំងការវេចខ្ចប់ផង ដែលពាក់ម៉ាក ដោយគ្មានការអនុញ្ញាតដែលដូចទៅនឹងម៉ាកដែលបានចុះបញ្ជីស្របច្បាប់ចំពោះទំនិញនេះ ឬដែលមិនអាចញែកដាច់ពីគ្នាបាននូវផ្នែកសំខាន់ពីម៉ាកនេះ ហើយដែលរំលោភបំពានសិទ្ធិម្ចាស់ម៉ាកនោះតាមច្បាប់នៃប្រទេសនាំចូល។

ខ. "ទំនិញថតចម្លងរំលោភសិទ្ធិអ្នកនិពន្ធ" មានន័យថា ទំនិញណាមួយ ដែលថតចម្លងដោយគ្មានការយល់ព្រមពីម្ចាស់សិទ្ធិឬពីបុគ្គលដែលទទួលបានការអនុញ្ញាតត្រឹមត្រូវពីម្ចាស់សិទ្ធិនៅក្នុងប្រទេសដែលផលិត ហើយដែលធ្វើឡើងដោយផ្ទាល់ឬដោយប្រយោលពីផលិតផលដែលត្រូវបានចម្លង បង្កើតបានជាការរំលោភបំពានលើសិទ្ធិអ្នកនិពន្ធឬសិទ្ធិប្រហាក់ប្រហែលតាមច្បាប់នៃប្រទេសនាំចូល។

ធ្វើឱ្យអាជ្ញាធរមានសមត្ថកិច្ចយល់ស្របថា ក្នុងច្បាប់នៃប្រទេសនាំចូល ពិតជាមានការរំលោភបំពានកម្មសិទ្ធិបញ្ញារបស់ម្ចាស់សិទ្ធិ និងតម្រូវឱ្យផ្តល់ការរៀបរាប់លម្អិតគ្រប់គ្រាន់ពីទំនិញដើម្បីឱ្យអាជ្ញាធរគយបានស្គាល់ដោយងាយ។ អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងដល់ដើមចោទក្នុងរយៈពេលមួយសមស្របថាតើអាជ្ញាធរនេះទទួលឬមិនទទួលពាក្យបណ្តឹង ហើយត្រូវជូនដំណឹង តាមការកំណត់របស់អាជ្ញាធរ អំពីរយៈពេលដែលអាជ្ញាធរគយ ត្រូវចាត់វិធានការ។

## មាត្រា៥៣

## ប្រាក់ធានា ឬ ការធានាដែលមានតម្លៃស្មើ

១- អាជ្ញាធរមានសមត្ថកិច្ចមានអំណាចតម្រូវឱ្យដើមចោទផ្តល់នូវប្រាក់ធានា ឬការធានាដែលមានតម្លៃស្មើ គ្រប់គ្រាន់ដើម្បីការពារចុងចម្លើយនិងការពារអាជ្ញាធរមានសមត្ថកិច្ច និងទប់ស្កាត់មិនឱ្យមានការរំលោភបំពាន ។ ប្រាក់ធានា ឬការធានាដែលមានតម្លៃស្មើ មិនត្រូវឱ្យរារាំងដោយមិនសមហេតុផល ដល់ការអនុវត្តន៍នីតិវិធីទាំងនេះ ។

២- អនុលោមតាមបណ្តឹងក្នុងផ្នែកនេះ នៅពេលដែលការដោះលែងទំនិញពាក់ព័ន្ធនឹងគំនូរឧស្សាហកម្ម ប្រកាសនីយបត្រតក្កកម្ម គំនូសបង្ហាញ ឬព័ត៌មានសម្ងាត់ ឱ្យចរាចរដោយសេរី ត្រូវបានព្យួរទុកដោយអាជ្ញាធរគយ លើមូលដ្ឋាននៃសេចក្តីសម្រេចដែលមិនចេញដោយអាជ្ញាធរតុលាការ ឬអាជ្ញាធរឯករាជ្យផ្សេងទៀត ហើយរយៈពេលដូចមានចែងក្នុងមាត្រា៥៥ បានផុតកំណត់ ដោយគ្មានផ្តល់ការដោះលែងជាបណ្តោះអាសន្នពីអាជ្ញាធរដែលទទួលបានអំណាចត្រឹមត្រូវទេ ហើយឱ្យតែគោរពតាមលក្ខខណ្ឌផ្សេងទៀតទាំងអស់នៃការនាំចូល ម្ចាស់ អ្នកនាំចូល ឬអ្នកទទួលទំនិញនេះ ត្រូវមានសិទ្ធិឱ្យដោះលែងទំនិញរបស់ខ្លួនដោយតម្កល់ប្រាក់ធានាគ្រប់គ្រាន់ដើម្បីការពារម្ចាស់សិទ្ធិពីការរំលោភបំពានណាមួយ។ ការបង់ប្រាក់ធានានេះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ ដំណោះស្រាយផ្សេងទៀតដែលមានសម្រាប់ម្ចាស់សិទ្ធិឡើយ។ ត្រូវយល់ថា ប្រាក់ធានានឹងត្រូវប្រគល់ឱ្យវិញ ប្រសិនបើម្ចាស់សិទ្ធិមិនបានអនុវត្តសិទ្ធិប្តឹងក្នុងរយៈពេលមួយសមស្រប។

## មាត្រា៥៤

## ការជូនដំណឹងអំពីការព្យួរទុក

អ្នកនាំចូលនិងដើមចោទ ត្រូវបានជូនដំណឹងជាបន្ទាន់ពីការព្យួរទុកការដោះលែងទំនិញតាមមាត្រា៥១។

## មាត្រា៥៥
## រយៈពេលនៃការព្យួរទុក

ក្នុងរយៈពេលមិនលើសពី ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកប្ដឹង បានទទួលព័ត៌មានអំពីការព្យួរទុក ប្រសិនបើអាជ្ញាធរគយបានទទួលព័ត៌មានថា ចំណាត់ការ ដែលនាំដល់សេចក្ដីសម្រេចដល់អង្គសេចក្ដីនៃរឿងក្ដីមិនត្រូវបានផ្ដួចផ្ដើមឡើងដោយភាគីមួយទៀត ក្រៅពីចុងចម្លើយ ឬថាអាជ្ញាធរដែលបានប្រគល់សិទ្ធិត្រឹមត្រូវ បានចេញវិធានការបណ្ដោះអាសន្នដែលពន្យារការព្យួរទុកការដោះលែងទំនិញ ទំនិញនោះនឹងត្រូវដោះលែង តែក្នុងករណីដែលលក្ខខណ្ឌផ្សេងៗទៀតសម្រាប់ការនាំចូលឬការនាំចេញត្រូវបានគោរព។ ក្នុងករណីសមស្រប រយៈពេលនេះ អាចត្រូវពន្យារ១០(ដប់)ថ្ងៃទៀតនៃថ្ងៃធ្វើការ។ ប្រសិនបើចំណាត់ការ ដែលនាំដល់សេចក្ដីសម្រេចដល់អង្គសេចក្ដីនៃរឿងក្ដី ត្រូវបានផ្ដួចផ្ដើមឡើង ការពិនិត្យឡើងវិញរួមទាំងសិទ្ធិតតាំងក្នុងសវនាការត្រូវបានរៀបចំឡើងតាមការស្នើសុំពីចុងចម្លើយ ដើម្បីសម្រេចក្នុងរយៈពេលមួយសមស្រប ថាតើវិធានការនេះត្រូវ កែតម្រូវ លុបចោល ឬតម្កល់។ ថ្វីបើមានចែងដូចខាងលើក៏ដោយ នៅពេលដែលការព្យួរការដោះលែងទំនិញត្រូវបានអនុវត្ត ឬបន្តអនុវត្តតាមវិធានការតុលាការបណ្ដោះអាសន្ន បទប្បញ្ញត្តិ កថាខណ្ឌទី៦នៃមាត្រា៥០ ត្រូវអនុវត្ត។

## មាត្រា៥៦
## សំណងចំពោះអ្នកនាំចូល និងចំពោះម្ចាស់ទំនិញ

អាជ្ញាធរពាក់ព័ន្ធ មានអំណាចបញ្ជាឱ្យដើមចោទ សង អ្នកនាំចូល អ្នកទទួល និងម្ចាស់ទំនិញនូវសំណងសមស្រប ចំពោះការខូតខាតនានាដែលកើតមានដោយការឃាត់ទុកខុសច្បាប់នៃទំនិញ ឬការឃាត់ទុកទំនិញដែលបានដោះលែងតាមមាត្រា៥៥។

## មាត្រា៥៧
## សិទ្ធិត្រួតពិនិត្យនិងសិទ្ធិទទួលព័ត៌មាន

ដោយមិនប៉ះពាល់ដល់កិច្ចការពារព័ត៌មានសម្ងាត់ សមាជិកទាំងឡាយត្រូវផ្ដល់អំណាចដល់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្ដល់ឱកាសគ្រប់គ្រាន់ដល់ម្ចាស់សិទ្ធិ ដើម្បីឱ្យទំនិញដែលត្រូវបានឃាត់ទុកដោយអាជ្ញាធរគយ ត្រូវបានត្រួតពិនិត្យ ដើម្បីបង្ហាញការអះអាងរបស់ខ្លួន ។ អាជ្ញាធរមានសមត្ថកិច្ចក៏មានអំណាចផ្ដល់ឱកាសដូចគ្នាដល់អ្នកនាំចូល ដើម្បីឱ្យទំនិញត្រូវបានត្រួតពិនិត្យ។ នៅពេលដែលមានសេចក្ដីសម្រេចជាវិជ្ជមានដល់អង្គសេចក្ដីនៃរឿងក្ដី សមាជិកទាំងឡាយអាចផ្ដល់អំណាចឱ្យអាជ្ញាធរមានសមត្ថកិច្ច ឱ្យផ្ដល់ព័ត៌មានដល់ម្ចាស់សិទ្ធិនូវឈ្មោះនិង

អាសយដ្ឋានរបស់អ្នកបញ្ជូន អ្នកនាំចូលនិងអ្នកទទួលទំនិញ និងបរិមាណទំនិញ ទាំងនេះ។

## មាត្រា៥៨

## សកម្មភាពដោយគ្មានបណ្ដឹង

នៅពេលដែលសមាជិកទាំងឡាយ តម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ច ធ្វើសកម្មភាពតាមគំនិតផ្ដួចផ្ដើមរបស់ខ្លួននិងព្យួរទុកការដោះលែងទំនិញ ដែលអាជ្ញាធរ ពិតជាបានទទួលភស្តុតាងថា កម្មសិទ្ធិបញ្ញាកំពុងត្រូវបានរំលោភបំពាន:

ក- អាជ្ញាធរមានសមត្ថកិច្ច អាចសុំព័ត៌មានបានគ្រប់ពេលវេលាពីម្ចាស់សិទ្ធិ ដែលអាចជួយឱ្យអាជ្ញាធរអាចអនុវត្តអំណាចទាំងនេះ។

ខ- អ្នកនាំចូល និងម្ចាស់សិទ្ធិ ត្រូវបានជូនដំណឹងជាបន្ទាន់អំពីការព្យួរទុកនេះ។ នៅពេលដែលអ្នកនាំចូល បានដាក់ពាក្យបណ្ដឹងប្រឆាំងនឹងការព្យួរទុកនៅអាជ្ញាធរមានសមត្ថកិច្ច ការការព្យួរទុកនេះ ត្រូវបំពេញតាមលក្ខខណ្ឌដូចគ្នានឹងមាត្រា៥៥ ហើយអាចកែប្រែតាមការចាំបាច់។

គ- សមាជិកទាំងឡាយត្រូវលើកលែងចំពោះតែអាជ្ញាធរនិងមន្ត្រីសាធារណៈ ពីការទទួលខុសត្រូវ លើវិធានការដោះស្រាយសមរម្យណាដែលត្រូវបានចាត់ ឬធ្វើឡើងដោយសុចរិត។

## មាត្រា៥៩

## វិធានការដោះស្រាយ

ដោយមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិក្នុងការបើកបណ្ដឹងរបស់ម្ចាស់សិទ្ធិ និងលើកលែងសិទ្ធិរបស់ចុងចម្លើយ ដើម្បីសុំឱ្យអាជ្ញាធរតុលាការត្រួតពិនិត្យឡើងវិញ អាជ្ញាធរមានសមត្ថកិច្ចមានអំណាចបញ្ជាឱ្យកម្ទេចឬបំផ្លាញចោលទំនិញល្មើស តាមគោលការណ៍ទាំងឡាយ ដែលមានចែងក្នុងមាត្រា៤៦។ ចំពោះទំនិញពាក់ម៉ាកក្លែងក្លាយ អាជ្ញាធរមិនត្រូវអនុញ្ញាតឱ្យនាំចេញសារជាថ្មីនូវទំនិញល្មើសក្នុងសភាពមិនផ្លាស់ប្ដូរឬដាក់ទំនិញទាំងនេះក្រោមនីតិវិធីគយផ្សេងទៀត លើកលែងតែក្នុងកាលៈទេសៈពិសេស។

## មាត្រា៦០

## ការនាំចូលក្នុងកម្រិតអប្បបរមា

សមាជិកទាំងឡាយ អាចដកចេញពីការអនុវត្តន៍នៃបទប្បញ្ញត្តិខាងលើ ចំពោះបរិមាណតិចតួចនៃទំនិញដែលគ្មានលក្ខណៈពាណិជ្ជកម្មដែលមានក្នុងអីវ៉ាន់ផ្ទាល់ខ្លួនរបស់អ្នកដំណើរ ឬក្នុងកញ្ចប់បញ្ញើតូចៗ។

## ផ្នែកទី៥ : នីតិវិធីព្រហ្មទណ្ឌ

### មាត្រា៦១

សមាជិកទាំងឡាយត្រូវចែងពីនីតិវិធិព្រហ្មទណ្ឌនិងទោសប្បញ្ញត្តិ ដើម្បីអនុវត្តយ៉ាងហោច ណាស់នៅក្នុងករណីនៃការក្លែងបន្លំម៉ាកដោយចេតនា ឬការលួចចម្លងសិទ្ធិអ្នកនិពន្ធក្នុងកម្រិត ពាណិជ្ជកម្ម។ ទណ្ឌកម្មទាំងឡាយ រួមមានការដាក់ពន្ធនាគារ និង/ឬទោសពិន័យជាប្រាក់ដែល សមស្របដើម្បីឱ្យមានភាពរាងចាល ហើយឱ្យស្របតាមកម្រិតនៃភាពធ្ងន់ធ្ងររបស់បទល្មើសដែល ពាក់ព័ន្ធ ។ ក្នុងករណីសមស្រប ទណ្ឌកម្មទាំងឡាយ រួមមានផងដែរ ការរឹបអូស ការដកហូត និង ការបំផ្លាញចោលទំនិញល្មើស និង សម្ភារៈនិងឧបករណ៍ទាំងឡាយដែលប្រើប្រាស់ជាចំបងដើម្បី ប្រព្រឹត្តបទល្មើស។ សមាជិកទាំងឡាយ អាចចែងអំពីនីតិវិធីព្រហ្មទណ្ឌនិងទោសប្បញ្ញត្តិ ដើម្បី អនុវត្តក្នុងករណីផ្សេងទៀតនៃការរំលោភបំពានកម្មសិទ្ធិបញ្ញា ជាពិសេសករណីដែលការ រំលោភបំពានទាំងនេះ ត្រូវបានធ្វើឡើងដោយចេតនានិងក្នុងកម្រិតពាណិជ្ជកម្ម។

## ជំពូកទី៤

## ការទទួលបាននិងការរក្សាសិទ្ធិកម្មសិទ្ធិបញ្ញា និងនីតិវិធីទាក់ទងនឹង ភាគីដែលពាក់ព័ន្ធ

### មាត្រា៦២

១- សមាជិកទាំងឡាយអាចតម្រូវឱ្យអនុលោមតាមនីតិវិធីនិងទម្រង់សមស្រប ជាលក្ខ ខណ្ឌដើម្បីទទួលបាន ឬរក្សាសិទ្ធិកម្មសិទ្ធិបញ្ញា ដូចមានចែងក្នុងផ្នែកទី២ ដល់ផ្នែកទី៦ នៃជំពូក ទី២។ នីតិវិធីនិងទម្រង់ទាំងនេះត្រូវអនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។

២- នៅពេលដែលការទទួលបានសិទ្ធិកម្មសិទ្ធិបញ្ញា ជាកម្មវត្ថុនៃលក្ខខណ្ឌក្នុងការផ្តល់ឱ្យ និងការចុះបញ្ជី សមាជិកទាំងឡាយត្រូវធានាថា នីតិវិធីផ្តល់ឬចុះបញ្ជី លើកលែងតែបានគោរព លក្ខខណ្ឌជាសារវន្តដើម្បីទទួលបានសិទ្ធិ អនុញ្ញាតឱ្យការផ្តល់ឬការចុះបញ្ជីសិទ្ធិត្រូវធ្វើឡើង ក្នុង រយៈពេលមួយសមស្របដើម្បីជៀសវាងការបន្ថយដោយគ្មានហេតុផលនៃរយៈពេលការពារ។

៣- មាត្រា៤ នៃអនុសញ្ញាទីក្រុងប៉ារីស(១៩៧៦) ត្រូវអនុវត្តដូចគ្នាប៉ុន្តែអាចកែប្រែតាម ការចាំបាច់ ចំពោះសេវាសញ្ញា។

៤- នៅពេលដែលច្បាប់របស់សមាជិកចែងអំពីនីតិវិធីនេះ នីតិវិធីពាក់ព័ន្ធនឹងការទទួល បាន ឬការរក្សាសិទ្ធិកម្មសិទ្ធិបញ្ញា និងការដកហូតតាមបែបរដ្ឋបាលនិងនីតិវិធីទាក់ទងនឹង ភាគីដែលពាក់ព័ន្ធ ដូចជា ការប្តឹងជំទាស់ ការដកហូត និងការលុបចោល ត្រូវគ្រប់គ្រងដោយ

គោលការណ៍ទូទៅ ដែលមានចែងក្នុងកថាខណ្ឌទី២ និងទី៣នៃមាត្រា៥១។

៥- សេចក្តីសម្រេចរដ្ឋបាលចុងក្រោយ ក្នុងនីតិវិធីណាមួយដូចមានចែងក្នុងកថាខណ្ឌទី៤ ត្រូវជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញ ដោយអាជ្ញាធរតុលាការ ឬអាជ្ញាធរដូចតុលាការ ។ ប៉ុន្តែគ្មានកាតព្វកិច្ចផ្តល់ឱកាសឱ្យត្រួតពិនិត្យឡើងវិញសេចក្តីសម្រេច ក្នុងករណីបណ្តឹងជំទាស់មិនបានសម្រេចឬការដកហូតតាមបែបរដ្ឋបាល ឱ្យតែមូលដ្ឋាននៃនីតិវិធីទាំងនេះ អាចជាកម្មវត្ថុនៃនីតិវិធីធ្វើមោឃៈភាព។

## ផ្នែកទី ៥ : ការទប់ស្កាត់និងដំណោះស្រាយវិវាទ

## មាត្រា៦៣

### តម្លាភាព

១- ច្បាប់និងបទបញ្ជា និងសេចក្តីសម្រេចតុលាការនិងរដ្ឋបាលចុងក្រោយដែលមានអានុភាពអនុវត្តទូទៅ ដែលសមាជិកមួយបានដាក់ឱ្យអនុវត្តទាក់ទងនឹងកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ (អត្ថិភាព វិសាលភាព ការទទួលបាន ការអនុវត្តន៍ និងការទប់ស្កាត់ការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញា) ត្រូវបោះពុម្ពផ្សាយ ឬនៅពេលដែលការបោះពុម្ពផ្សាយនេះ មិនអាចធ្វើទៅបាន ត្រូវដាក់ឱ្យមានជាសាធារណៈជាភាសាជាតិ ដើម្បីឱ្យរដ្ឋាភិបាលនិងម្ចាស់សិទ្ធិបានដឹង។ កិច្ចព្រមព្រៀងទាំងឡាយ ដែលទាក់ទងនឹងកម្មវត្ថុនៃកិច្ចព្រមព្រៀងនេះ ដែលនៅជាធរមានរវាងរដ្ឋាភិបាលឬភ្នាក់ងាររដ្ឋាភិបាលនៃសមាជិកមួយ និង រដ្ឋាភិបាលឬភ្នាក់ងាររដ្ឋាភិបាលនៃសមាជិកមួយផ្សេងទៀត ក៏ត្រូវបោះពុម្ពផ្សាយផងដែរ។

២- សមាជិកទាំងឡាយ ត្រូវជូនដំណឹងអំពីច្បាប់និងបទបញ្ជា ដូចមានចែងក្នុងកថាខណ្ឌទី១ ដល់ក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញាដើម្បីជួយក្រុមប្រឹក្សានេះក្នុងការត្រួតពិនិត្យការប្រព្រឹត្តទៅនៃកិច្ចព្រមព្រៀងនេះ។ ក្រុមប្រឹក្សាត្រូវព្យាយាមកាត់បន្ថយបន្ទុកជាអប្បបរមាលើសមាជិកទាំងឡាយក្នុងការអនុវត្តន៍កាតព្វកិច្ចនេះ និងអាចសម្រេចបដិសេធកាតព្វកិច្ចក្នុងការជូនដំណឹងអំពីច្បាប់និងបទបញ្ជា ដោយផ្ទាល់ទៅក្រុមប្រឹក្សា ប្រសិនបើ ការប្រឹក្សាយោបល់ជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក អំពីការបង្កើតការចុះបញ្ជីរួមដែលមានបញ្ចូលច្បាប់និងបទបញ្ជាទាំងនេះ ទទួលបានជោគជ័យ។ ចំពោះរឿងនេះក្រុមប្រឹក្សាក៏ត្រូវពិចារណាផងដែរ ទៅលើវិធានការណាមួយដែលអាចទាមទារទាក់ទងនឹងការជូនដំណឹងតាមកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងនេះ ដែលកើតចេញពីបទប្បញ្ញត្តិនៃមាត្រា៦ ស្ទួន (៣) នៃអនុសញ្ញាទីក្រុងប៉ារីស(១៩៦៧)។

៣- ដើម្បីឆ្លើយតបចំពោះសំណើជាលាយលក្ខណ៍អក្សររបស់សមាជិកមួយផ្សេងទៀត សមាជិកនីមួយៗ ត្រូវរៀបចំផ្តល់ព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី១។ សមាជិកមួយ ដែលមានហេតុផលគួរឱ្យជឿថា សេចក្តីសម្រេចតុលាការ ឬសេចក្តីសម្រេចរដ្ឋបាល ឬកិច្ចព្រមព្រៀងទ្វេភាគីជាក់លាក់ក្នុងវិស័យកម្មសិទ្ធិបញ្ញា ប៉ះពាល់ដល់សិទ្ធិរបស់ខ្លួនក្នុងកិច្ចព្រមព្រៀងនេះ ក៏អាចស្នើសុំជាលាយលក្ខណ៍អក្សរដើម្បីឱ្យគេផ្តល់ឱ្យ ឬឱ្យទទួលដំណឹងក្នុងលក្ខណៈលម្អិតគ្រប់គ្រាន់អំពីសេចក្តីសម្រេចតុលាការ ឬសេចក្តីសម្រេចរដ្ឋបាល ឬកិច្ចព្រមព្រៀងទ្វេភាគីជាក់លាក់ទាំងនេះ។

៤- កថាខណ្ឌទី១ ទី២ និងទី៣ មិនតម្រូវឱ្យសមាជិកទាំងឡាយបើកបង្ហាញព័ត៌មានសម្ងាត់ដែលអាចរារាំងដល់ការអនុវត្តន៍ច្បាប់ ឬបើមិនដូច្នោះទេ ផ្ទុយនឹងផលប្រយោជន៍សាធារណៈ ឬធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់សហគ្រាសណាមួយ ទោះជាសាធារណៈឬឯកជន។

## មាត្រា៦៤

## ការដោះស្រាយវិវាទ

១- បទប្បញ្ញត្តិទាំងឡាយនៃមាត្រា XXII និង XXIII នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ ដូចដែលបានបញ្ជាក់បន្ថែម និងបានអនុវត្តដោយអនុស្សរណៈនៃការដោះស្រាយវិវាទ ត្រូវអនុវត្តដើម្បីប្រឹក្សាយោបល់ និងដោះស្រាយវិវាទក្នុងកិច្ចព្រមព្រៀងនេះ លើកលែងតែមានការចែងផ្សេងក្នុងកិច្ចព្រមព្រៀងនេះ។

២- អនុកថាខណ្ឌទី១ (ខ) និងទី១ (គ) នៃមាត្រាXXIII នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយនិងពាណិជ្ជកម្ម ១៩៩៤ មិនត្រូវអនុវត្តចំពោះការដោះស្រាយវិវាទក្នុងកិច្ចព្រមព្រៀងនេះក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក។

៣- ក្នុងរយៈពេលដូចមានចែងក្នុងកថាខណ្ឌទី២ ក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញាត្រូវពិនិត្យវិសាលភាព និងបែបបទបណ្តឹងដែលមានចែងក្នុងអនុកថាខណ្ឌទី១(ខ) និងទី១(គ) នៃមាត្រា XXIII នៃកិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្ម ១៩៩៤ ដែលបានធ្វើអនុលោមតាមកិច្ចព្រមព្រៀងនេះ ហើយបញ្ជូនអនុសាសន៍របស់ខ្លួនទៅសន្និសីទថ្នាក់រដ្ឋមន្ត្រី ដើម្បីអនុម័ត។ សេចក្តីសម្រេចណាមួយនៃសន្និសីទថ្នាក់រដ្ឋមន្ត្រីដើម្បីអនុម័តអនុសាសន៍ទាំងនេះ ឬដើម្បីពន្យាររយៈពេលក្នុងកថាខណ្ឌទី២ ត្រូវធ្វើឡើងដោយ

ឯកច្ឆ័នតែប៉ុណ្ណោះ ហើយអនុសាសន៍ដែលបានអនុម័ត ត្រូវមានអានុភាពចំពោះគ្រប់សមាជិកទាំងអស់ ដោយមិនចាំបាច់មានដំណើរការយល់ព្រមជាផ្លូវការផ្សេងទៀតឡើយ។

# ជំពូកទី៦

# បទប្បញ្ញត្តិអន្តរកាល

## មាត្រា៦៥

## បទប្បញ្ញត្តិអន្តរកាល

១- លើកលែងបទប្បញ្ញត្តិនៃកថាខណ្ឌទី២ ទី៣ និងទី៤ គ្មានសមាជិកណា ត្រូវតម្រូវឱ្យអនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ មុនផុតកំណត់រយៈពេលទូទៅ១(មួយ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀអង្គការពាណិជ្ជកម្មពិភពលោក។

២- សមាជិកប្រទេសកំពុងអភិវឌ្ឍមានសិទ្ធិពន្យាររយៈពេល៤(បួន)ឆ្នាំបន្ថែមទៀតពីកាលបរិច្ឆេទនៃការអនុវត្តន៍ ដូចដែលបានកំណត់ក្នុងកថាខណ្ឌទី១នៃកិច្ចព្រមព្រៀងនេះ លើកលែងតែមាត្រា៣ មាត្រា៤ និងមាត្រា៥។

៣- សមាជិកផ្សេងទៀតណាមួយ ដែលស្ថិតក្នុងដំណើរការផ្លាស់ប្តូរពីសេដ្ឋកិច្ចផែនការទៅជាសេដ្ឋកិច្ចទីផ្សារសេរី និងកំពុងកែទម្រង់រចនាសម្ព័ន្ធប្រព័ន្ធកម្មសិទ្ធិបញ្ញា ហើយកំពុងជួបប្រទះបញ្ហាពិសេសក្នុងការរៀបចំនិងការអនុវត្តន៍ច្បាប់និងបទបញ្ជាកម្មសិទ្ធិបញ្ញា ក៏អាចទទួលអត្ថប្រយោជន៍ ពីរយៈពេលនៃការពន្យារដូចមានចែងក្នុងកថាខណ្ឌទី២។

៤- ក្នុងករណីដែលសមាជិកប្រទេសកំពុងអភិវឌ្ឍត្រូវតម្រូវដោយកិច្ចព្រមព្រៀងនេះ ឱ្យពង្រីកកិច្ចការពារប្រកាសនីយបត្រតក្កកម្មដែលជាផលិតផល ដល់វិស័យបច្ចេកវិទ្យា ដែលមិនអាចការពារបានក្នុងដែនដីរបស់ខ្លួន តាមកាលបរិច្ឆេទទូទៅនៃការអនុវត្តន៍កិច្ចព្រមព្រៀងនេះចំពោះសមាជិកនេះ ដូចដែលបានកំណត់ក្នុងកថាខណ្ឌទី២ សមាជិកនេះអាចពន្យារការអនុវត្តន៍បទប្បញ្ញត្តិទាំងឡាយ ស្តីពីប្រកាសនីយបត្រតក្កកម្មដែលជាផលិតផល ក្នុងផ្នែកទី៥នៃជំពូកទី២ចំពោះវិស័យបច្ចេកវិទ្យានោះ ក្នុងរយៈពេល៥(ប្រាំ)ឆ្នាំបន្ថែមទៀត។

៥- សមាជិកមួយ ដែលប្រើប្រាស់រយៈពេលអន្តរកាលក្នុងកថាខណ្ឌទី១ ទី២ ទី៣ ឬទី៤ ត្រូវធានាថា ការផ្លាស់ប្តូរណាមួយក្នុងច្បាប់ បទបញ្ជា និងការអនុវត្តន៍ របស់ខ្លួន ដែលបានធ្វើឡើងក្នុងរយៈពេលនេះ មិនអាចបន្ថយកម្រិតអនុលោមភាពចំពោះបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀងនេះឡើយ។

## មាត្រា៦៦

## សមាជិកប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុត

១- ដោយផ្អែកទៅលើភាពចាំបាច់និងលក្ខខណ្ឌពិសេសនៃសមាជិកប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុត ការលំបាកផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុនិងរដ្ឋបាល និង តម្រូវការឱ្យមានភាពដែលអាចបត់បែនបាន ក្នុងការបង្កើតមូលដ្ឋានបច្ចេកវិទ្យាមួយដែលអាចជឿជាក់បាន សមាជិកទាំងនេះមិនតម្រូវឱ្យអនុវត្តបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ លើកលែងតែមាត្រា៣ មាត្រា៤ និងមាត្រា៥ ក្នុងរយៈពេល១០(ដប់)ឆ្នាំ រាប់ចាប់ពីកាលបរិច្ឆេទនៃការអនុវត្តន៍ដូចកំណត់ក្នុងកថាខណ្ឌទី១នៃមាត្រា៦៥។ ដោយមានសំណើសមហេតុផលពីសមាជិកប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុត ក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា ត្រូវយល់ព្រមពន្យាររយៈពេលនេះ។

២- សមាជិកប្រទេសអភិវឌ្ឍត្រូវលើកទឹកចិត្តសហគ្រាស និងស្ថាប័នក្នុងដែនដីរបស់ខ្លួនក្នុងគោលបំណងជម្រុញ និងលើកទឹកចិត្តចំពោះការផ្ទេរបច្ចេកវិទ្យាទៅសមាជិកប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុត ដើម្បីអាចឱ្យប្រទេសទាំងនេះ បង្កើតមូលដ្ឋានបច្ចេកវិទ្យារឹងមាំនិងអាចជឿជាក់បាន។

## មាត្រា៦៧

## សហប្រតិបត្តិការបច្ចេកទេស

ដើម្បីសម្រួលដល់ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ តាមសំណើ និង តាមបែបបទនិងលក្ខខណ្ឌដែលបានព្រមព្រៀងទៅវិញទៅមក សមាជិកប្រទេសអភិវឌ្ឍត្រូវផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីជួយដល់សមាជិកប្រទេសកំពុងអភិវឌ្ឍនិងសមាជិកប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុតទាំងឡាយ ។ កិច្ចសហប្រតិបត្តិការនេះ រួមមាន ជំនួយក្នុងការរៀបចំច្បាប់ និងបទបញ្ញាស្តីពីកិច្ចការពារនិងការអនុវត្តន៍កម្មសិទ្ធិបញ្ញា ក៏ដូចជាស្តីពីការទប់ស្កាត់ការរំលោភបំពាន និងត្រូវបញ្ចូលផងដែរនូវជំនួយចំពោះការបង្កើតនិងការពង្រឹងការិយាល័យ និងភ្នាក់ងារក្នុងស្រុកទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាទាំងនេះ រួមទាំងបណ្តុះបណ្តាលបុគ្គលិក។

# ជំពូកទី៧
# បទប្បញ្ញត្តិស្តីពីស្ថាប័ន អវសានប្បញ្ញាត្តិ
## មាត្រា៦៨
## ក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញា

ក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញាត្រូវត្រួតពិនិត្យការអនុវត្តន៍កិច្ចព្រមព្រៀងនេះ និងជាពិសេសការគោរពកាតព្វកិច្ចរបស់សមាជិកទាំងឡាយតាមកិច្ចព្រមព្រៀងនេះ ហើយត្រូវផ្តល់ឱកាសដល់សមាជិកក្នុងការប្រឹក្សាយោបល់លើបញ្ហាដែលពាក់ព័ន្ធនឹងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា។ ក្រុមប្រឹក្សានេះត្រូវអនុវត្តភារៈកិច្ចផ្សេងទៀតដែលសមាជិកទាំងឡាយបានផ្តល់ឱ្យ ហើយជាពិសេសក្រុមប្រឹក្សានេះត្រូវផ្តល់ជំនួយណាមួយដែលសមាជិកបានស្នើឡើងក្នុងបរិបទនៃនីតិវិធីដោះស្រាយវិវាទ។ ក្នុងការអនុវត្តន៍មុខងាររបស់ខ្លួន ក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មដែលទាក់ទងនឹងកម្មសិទ្ធិបញ្ញាអាចប្រឹក្សាយោបល់ជាមួយនិងសុំព័ត៌មានពីប្រភពណាមួយដែលសមស្រប។ ដោយបានប្រឹក្សាយោបល់ជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក្រុមប្រឹក្សានេះ ត្រូវខិតខំបង្កើតបទប្បញ្ញត្តិ សមស្របក្នុងរយៈពេល១(មួយ)ឆ្នាំបន្ទាប់ពីកិច្ចប្រជុំទីមួយរបស់ខ្លួន ដើម្បីធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គភាពនានានៃអង្គការនោះ។

## មាត្រា៦៩
## សហប្រតិបត្តិការអន្តរជាតិ

សមាជិកទាំងឡាយ យល់ព្រមសហប្រតិបត្តិការគ្នាទៅវិញទៅមក ដើម្បីបំបាត់ចោលពាណិជ្ជកម្មអន្តរជាតិនូវទំនិញដែលរំលោភកម្មសិទ្ធិបញ្ញា។ ដើម្បីសម្រេចគោលបំណងនេះបានសមាជិក ត្រូវបង្កើតនិងត្រូវជូនដំណឹងអំពីចំនុចទំនាក់ទំនងក្នុងរដ្ឋបាលរបស់ខ្លួន ហើយត្រូវត្រៀមខ្លួនដើម្បីផ្លាស់ប្តូរព័ត៌មានស្តីពីការធ្វើពាណិជ្ជកម្មលើទំនិញល្មើស។ ជាពិសេស សមាជិកត្រូវ ជម្រុញការផ្លាស់ប្តូរព័ត៌មាននិងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរគយ ទាក់ទងនឹងការធ្វើពាណិជ្ជកម្មលើទំនិញក្លែងបន្លំម៉ាកនិងទំនិញលួចចម្លងដែលរំលោភសិទ្ធិអ្នកនិពន្ធ។

## មាត្រា៧០
## កិច្ចការពារកម្មវត្ថុដែលមានស្រាប់

១- កិច្ចព្រមព្រៀងនេះ មិនបង្កើតកាតព្វកិច្ចចំពោះសកម្មភាពទាំងឡាយដែលបានកើតឡើងមុនកាលបរិច្ឆេទនៃការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ចំពោះសមាជិកនោះ។

២- លើកលែងតែមានចែងក្នុងកិច្ចព្រមព្រៀងនេះ កិច្ចព្រមព្រៀងនេះបង្កើតកាតព្វកិច្ច ចំពោះកម្មវត្ថុទាំងអស់ដែលមានតាមកាលបរិច្ឆេទនៃការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ចំពោះសមាជិកនោះ ហើយដែលត្រូវបានការពារក្នុងប្រទេសជាសមាជិកនោះតាមកាលបរិច្ឆេទនេះ ឬ ដែលបំពេញ ឬនឹងបំពេញនាពេលក្រោយនូវលក្ខខណ្ឌដើម្បីការពារតាមបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។ ចំពោះកថាខណ្ឌនេះនិងកថាខណ្ឌទី៣និងទី៤ កាតព្វកិច្ចទាក់ទងនឹងសិទ្ធិអ្នកនិពន្ធចំពោះស្នាដៃដែលមានស្រាប់ នឹងត្រូវកំណត់តែតាមមាត្រា១៨នៃអនុសញ្ញាទីក្រុងប៊ែន(១៩៧១) ហើយកាតព្វកិច្ចចំពោះសិទ្ធិផលិតករហ្វូណូក្រាមនិងអ្នកសម្តែងក្នុងហ្វូណូក្រាមដែលមានស្រាប់ នឹងត្រូវកំណត់តែតាមមាត្រា១៨នៃអនុសញ្ញាទីក្រុងប៊ែន(១៩៧១) ដូចដែលអាចអនុវត្តតាមកថាខណ្ឌទី៦ មាត្រា១៤ នៃកិច្ចព្រមព្រៀងនេះ។

៣- គ្មានកាតព្វកិច្ចដើម្បីផ្តល់កិច្ចការពារឡើងវិញ ចំពោះកម្មវត្ថុ ដែលតាមកាលបរិច្ឆេទនៃការអនុវត្តន៍កិច្ចព្រមព្រៀងនេះចំពោះសមាជិកនោះ បានក្លាយជាទ្រព្យសម្បត្តិសាធារណៈជន។

៤- ចំពោះសកម្មភាពណាមួយដែលពាក់ព័ន្ធនឹងវត្ថុជាក់លាក់ ដែលមានក្នុងកម្មវត្ថុដែលបានការពារ ដែលបានរំលោភបំពានសិទ្ធិតាមច្បាប់ដែលស្របនឹងកិច្ចព្រមព្រៀងនេះ ហើយដែលត្រូវបានចាប់ផ្តើម ឬចំពោះសកម្មភាពទាំងឡាយដែលបានអនុវត្តការវិនិយោគសំខាន់ មុនកាលបរិច្ឆេទទទួលយកកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោកដោយសមាជិកនោះ សមា-ជិកណាមួយ អាចចែងអំពីការកម្រិតវិធានការដោះស្រាយដែលម្ចាស់សិទ្ធិអាចទទួល ចំពោះការបន្តសកម្មភាព បន្ទាប់ពីកាលបរិច្ឆេទអនុវត្តកិច្ចព្រមព្រៀងនេះចំពោះសមាជិកនោះ។ ប៉ុន្តែក្នុងករណីទាំងនេះ សមាជិកនោះ ត្រូវចែងយ៉ាងហោចណាស់ឱ្យមានការបង់ប្រាក់សំណងសមរម្យ។

៥- សមាជិកមួយមិនតម្រូវអោយអនុវត្តបទប្បញ្ញត្តិនៃមាត្រា១១និងបទប្បញ្ញត្តិកថាខណ្ឌទី៤នៃមាត្រា១៤ ចំពោះស្នាដៃដើមឬស្នាដៃចម្លង ដែលបានទិញមុនកាលបរិច្ឆេទនៃការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ចំពោះសមាជិកនោះ ។

៦- សមាជិកទាំងឡាយ មិនតម្រូវឱ្យអនុវត្តមាត្រា៣១ ឬ លក្ខខណ្ឌក្នុងកថាខណ្ឌទី១នៃមាត្រា២៧ ដែលសិទ្ធិលើប្រកាសនីយបត្រតក្កកម្មត្រូវបានផ្តល់ឱ្យដោយគ្មានការរើសអើងក្នុងវិស័យបច្ចេកវិទ្យា ចំពោះការប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីម្ចាស់សិទ្ធិនៅពេលដែលការអនុញ្ញាតឱ្យប្រើប្រាស់នេះ ត្រូវបានផ្តល់ឱ្យដោយរដ្ឋាភិបាល មុនកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងនេះ ត្រូវបានទទួលស្គាល់។

៧- ក្នុងករណីដែលកិច្ចការពារសិទ្ធិកម្មសិទ្ធិបញ្ញា ទាមទារឱ្យចុះបញ្ជី ការដាក់ពាក្យសុំកិច្ចការពារដែលកំពុងព្យួរតាមកាលបរិច្ឆេទនៃការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ចំពោះសមាជិកនេះ ត្រូវបានអនុញ្ញាតឱ្យធ្វើវិសោធនកម្ម ដើម្បីសុំឱ្យមានកិច្ចការពារកាន់តែប្រសើរដូចមានចែងក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ។ វិសោធនកម្មនេះមិនត្រូវបញ្ចូលបញ្ហាថ្មីឡើយ។

៨- ក្នុងករណីដែលសមាជិកមួយមិនអាចការពារ តាមកាលបរិច្ឆេទនៃការចូលជាធរមានរបស់កិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ប្រកាសនីយបត្រតក្កកម្មចំពោះផលិតផលឱសថនិងផលិតផលគីមីកសិកម្ម ស្របតាមកាតព្វកិច្ចនៃមាត្រា២៧ទេ សមាជិកនេះត្រូវ :

ក- ថ្វីបើមានចែងក្នុងបទប្បញ្ញត្តិនៃជំពូកទី៦ក៏ដោយ ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ផ្តល់នូវមធ្យោបាយដើម្បីដាក់សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មចំពោះតក្កកម្មនេះ

ខ- ចាប់ពីកាលបរិច្ឆេទនៃការអនុវត្តន៍កិច្ចព្រមព្រៀងនេះ អនុវត្តចំពោះសំណុំលិខិតស្នើសុំទាំងនេះ នូវលក្ខខណ្ឌដែលអាចទទួលបានប្រកាសនីយបត្រតក្កកម្ម ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះ ប្រសិនបើលក្ខខណ្ឌទាំងនេះកំពុងត្រូវបានអនុវត្តតាមកាលបរិច្ឆេទនៃការដាក់ពាក្យសុំចុះបញ្ជីក្នុងប្រទេសជាសមាជិកនោះ ឬពេលមាននិងពេលដែលអះអាងសិទ្ធិអាទិភាព គឺកាលបរិច្ឆេទអាទិភាពនៃសំណុំលិខិតស្នើសុំ និង

គ- ផ្តល់កិច្ចការពារប្រកាសនីយបត្រតក្កកម្ម អនុលោមតាមកិច្ចព្រមព្រៀងនេះ ចាប់ពីពេលផ្តល់ប្រកាសនីយបត្រតក្កកម្ម ហើយចំពោះរយៈពេលប្រកាសនីយបត្រតក្កកម្មដែលនៅសល់ ដែលបានកំណត់ចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យសុំតាមមាត្រា៣៣នៃកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះសំណុំលិខិតស្នើសុំណាដែលបានបំពេញលក្ខខណ្ឌការពារ តាមអនុកថាខណ្ឌ (ខ)។

៩- នៅពេលដែលផលិតផលមួយជាកម្មវត្ថុនៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មក្នុងសមាជិកមួយតាមកថាខណ្ឌទី៨(ក) សិទ្ធិទីផ្សារផ្តាច់មុខ ត្រូវផ្តល់ឱ្យ ថ្វីបើមានចែងក្នុង បទប្បញ្ញត្តិនៃជំពូកទី៦ក៏ដោយ ក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីទទួលបានការអនុញ្ញាតដាក់លក់លើទីផ្សារក្នុងប្រទេសជាសមាជិកនោះ ឬរហូតដល់ពេលប្រកាសនីយបត្រតក្កកម្មដែលជាផលិតផល ត្រូវបានផ្តល់ឱ្យ ឬត្រូវបានបដិសេធក្នុងប្រទេសជាសមាជិកនោះ ដោយយករយៈពេល ណាដែលខ្លីជាងគេ ឱ្យតែបន្ទាប់ពីការចូលជាធរមាននៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ត្រូវបានដាក់ នឹងមានការផ្តល់ប្រកាសនីយបត្រតក្ក-

កម្មចំពោះផលិផលនោះក្នុងសមាជិកមួយផ្សេងទៀត ហើយទទួលបានការអនុញ្ញាតឱ្យលក់លើទីផ្សារ ក្នុងសមាជិកមួយផ្សេងទៀតនោះ។

## មាត្រា៧១
## ការត្រួតពិនិត្យ និង វិសោធនកម្ម

១- ក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ត្រូវត្រួតពិនិត្យការអនុវត្តន៍កិច្ចព្រមព្រៀងនេះបន្ទាប់ពីផុតកំណត់រយៈពេល អន្តរកាលដូចដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៦៥។ ផ្អែកលើបទពិសោធដែលទទួលបានក្នុងការអនុវត្តន៍របស់ខ្លួន ក្រុមប្រឹក្សានេះត្រូវត្រួតពិនិត្យកិច្ចព្រមព្រៀងនេះក្នុងរយៈពេល២(ពីរ)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទនេះ និងក្នុងចន្លោះពេលដូចគ្នាបន្ទាប់មកទៀត។ ក្រុមប្រឹក្សានេះក៏អាចត្រួតពិនិត្យផងដែរពេលដែលមានការវិវឌ្ឍន៍ថ្មីដែលពាក់ព័ន្ធណាមួយ ដែលអាចធ្វើឱ្យមានការកែប្រែ ឬវិសោធនកម្មកិច្ចព្រមព្រៀងនេះ។

២- វិសោធនកម្ម ដែលគ្រាន់តែបម្រើគោលបំណងនៃការកែតម្រូវឱ្យមានកិច្ចការពារកម្មសិទ្ធិបញ្ញាកាន់តែខ្ពស់ និងដែលអាចអនុវត្តបានស្របតាមកិច្ចព្រមព្រៀងពហុភាគីផ្សេងទៀត ហើយដែលត្រូវបានទទួលយកក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងទាំងនេះ ដោយសមាជិកទាំងអស់នៃអង្គការពាណិជ្ជកម្មពិភពលោក អាចត្រូវដាក់បញ្ចូលក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីដើម្បីឱ្យមានការចាត់វិធានការស្របតាមកថាខណ្ឌទី៦នៃមាត្រាXនៃកិច្ចព្រមព្រៀងអង្គការពាណិជ្ជកម្មពិភពលោក ដោយផ្អែកលើមូលដ្ឋាននៃសំណើជាឯកច្ឆ័នរបស់ក្រុមប្រឹក្សាសម្រាប់ទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា។

## មាត្រា៧២
## ខដាក់លក្ខខណ្ឌ

មិនអាចបង្កើតខដាក់លក្ខខណ្ឌ ចំពោះបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះដោយគ្មានការយល់ព្រមពីសមាជិកផ្សេងទៀតឡើយ។

## មាត្រា៧៣
## ការលើកលែងទាក់ទងនឹងបញ្ហាសន្តិសុខ

គ្មានបទប្បញ្ញត្តិណាក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយដើម្បីៈ

ក- តម្រូវឱ្យសមាជិកមួយបង្ហើបបង្ហាញព័ត៌មានណាមួយ ដែលសមាជិកនេះយល់ ថាផ្ទុយនឹងផលប្រយោជន៍សន្តិសុខជាសារវន្តរបស់ខ្លួន។

ខ-ទប់ស្កាត់សមាជិកមួយមិនឱ្យចាត់វិធានការណាមួយ ដែលសមាជិកនេះយល់ថាចាំបាច់ដើម្បីការពារផលប្រយោជន៍សន្តិសុខជាសារវន្តរបស់ខ្លួន:

(i) ទាក់ទងនឹងសំភារៈដែលអាចបំបែកធាតុនុយក្លេអ៊ែ ឬសម្ភារៈដែលប្រើសម្រាប់ផលិតសារធាតុទាំងនេះ

(ii) ទាក់ទងនឹងការចរាចរណ៍អាវុធ គ្រាប់រំសេវ និងឧបករណ៍ធ្វើសង្គ្រាម និងទាក់ទងនឹងចរាចរទំនិញ និងសំភារៈផ្សេងទៀត ដែលមានគោលដៅ ដោយផ្ទាល់ឬដោយប្រយោលក្នុងការផ្គត់ផ្គង់គ្រឹះស្ថានយោធា

(iii) ក្នុងពេលមានសង្គ្រាមឬពេលមានអាសន្នក្នុងទំនាក់ទំនងអន្តរជាតិ។

គ- ទប់ស្កាត់សមាជិកមួយមិនឱ្យចាត់វិធានការ តាមកាតព្វកិច្ចរបស់ខ្លួនក្រោមធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ ដើម្បីរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។